ព្រឹត្តិបត្រ ៨ ២០២៣ លេខពិសេស ឆ្នាំទី១៧

# នារីរតនៈ

# NEARY RATTANAK NEWSLETTER




## កិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី២ ដែលដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## អបអរសាទរ
## ទិវាអន្តរជាតិនារី ៨មីនា
## ខួបលើកទី១១២

ក្រោមប្រធានបទ៖

## "ស្ត្រីរួមគ្នា ថែរក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍ ក្នុងយុគសម័យឌីជីថល"

ចេញផ្សាយដោយ នាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី
info@mowa.gov.kh www.mowa.gov.kh facebook.com/mowa.gov.kh youtube.com/mowacambodiaofficial

## គណៈកម្មការត្រួតពិនិត្យ

| | | |
|---|---|---|
| លោកជំទាវ | ម៉ាន ចិន្តា | រដ្ឋលេខាធិការ |
| លោកជំទាវ | ប៊ុន ពុទ្ធី | អនុរដ្ឋលេខាធិការ |
| ឯកឧត្តម | ថេ ឈុនហាក់ | អគ្គនាយក |
| លោកជំទាវ | កេត ម៉ារឌី | ទីប្រឹក្សា |
| លោកស្រី | ដើក ហន | អគ្គនាយករង |

## គណៈកម្មការនិពន្ធ និងក្រាហ្វិចកុំព្យូទ័រ

លោកស្រី ប៉ែន គន្ធា
លោកស្រី អ៊ុង ខេមរា
លោកស្រី ប្រាក់ សោភា
លោកស្រី ថា បូណារី
លោក ប៉ោង សុធី
លោក ប៉េង សុធីណា
លោកស្រី តែ សុខខេង
លោកស្រី មាស ពិសី
លោកស្រី ឆយ ឡាវី
លោក អ៊ិន បុត្រ
លោក មឿន ឆេង
លោក សឿន វណ្ណារ៉ូ
លោក ហ៊ត ចំរើន
លោក ប៉ែន ជា

# មាតិកា


-ក្រាបបង្គំទូលថ្វាយសម្តេចព្រះមហាក្សត្រី.........................................០១
-ព្រះរាជសារសម្តេចព្រះមហាក្សត្រី.................................................០២
-សម្តេចតេជោ ហ៊ុន សែន..........ក្នុងកិច្ចប្រជុំកំពូលស្ត្រីអាស៊ាន.............០៥
-សម្តេចតេជោ ហ៊ុន សែន........ចុះសួរសុខទុក្ខដល់កុមារី/យុវតី............០៨
-សកម្មភាពកាកបាទក្រហមកម្ពុជា..................................................១០
-លទ្ធផលការងារប្រចាំឆ្នាំ២០២២....... របស់ក្រសួងកិច្ចការនារី............១២
-វេទិកា និងពិធីប្រគល់ពានរង្វាន់សហគ្រិនស្ត្រីអាស៊ាន....លើកទី២.......១៨
-សកម្មភាពថ្នាក់ដឹកនាំក្រសួងកិច្ចការនារី
-យុទ្ធនាការ ១៦ថ្ងៃ បញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ..................២២
-ពិធីប្រគល់ពានរង្វាន់សហគ្រិនវ័យក្មេងអាស៊ានលើកទី៧ ..................២៤
-សន្និបាតបូកសរុបលទ្ធផលការងារគណៈកម្មាធិការជាតិ.....................២៥
-សិក្ខាសាលាពិគ្រោះយោបល់ និងចែករំលែកបទពិសោធន៍.................២៦
-ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "បន្ទប់បំបៅដោះកូន"..............២៨
-ទស្សនៈយល់ដឹងក្រោមមូលបទ«ស្ត្រីរួមគ្នារក្សាសុខសន្តិភាព.............៣២
-ពីក្មេងស្រីចូលចិត្តលេងឡានបញ្ជា ទៅជានិស្សិត.............................៣៥
-ព្រឹត្តិការណ៍ស៊ីហ្គេមលើកទី៣២ និង អាស៊ានប៉ារ៉ាហ្គេម.....................៣៦
-មានតែចំណេះវិជ្ជាទេ ដែលជាស្ពាននាំយើងចេញពី...........................៣៨
-កែច្នៃផុងសំរាមពីសំបកកង់ឡានដែលគេបោះបង់ចោល.....................៤០
-តារាងស្ថិតិសិស្សប្រឡងជាប់សញ្ញាប័ត្រមធ្យម...................................៤១
-ស្ថិតិស្ត្រីក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៥ (២០២២)................... ៤២
-ស្ត្រី និងភាពជាអ្នកដឹកនាំថ្នាក់ រាជធានី-ខេត្ត.................................. ៤៣
-ស្ថិតិមន្ត្រីរាជការស៊ីវិលឆ្នាំ២០២០១............................................៤៤


# អារម្ភកថា

ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣នេះ ក្រសួងកិច្ចការនារីបានសម្រេចយកមូលបទ «**ស្ត្រីរួមគ្នា រក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍ ក្នុងយុគសម័យឌីជីថល**» ក្នុងការរំលេចពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា បង្កលក្ខណៈឱ្យតម្លៃនៃការចូលរួមរបស់ស្ត្រីដែលមិនអាចកាត់ថ្លៃបានក្នុងការថែរក្សាសុខសន្តិភាព ក៏ដូចជាកំពុងចូលរួមយ៉ាងសកម្ម ក្នុងការពន្លឿនកិច្ចអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសនៅក្នុងយុគសម័យឌីជីថល ក្រោយវិបត្តិកូវីដ-១៩ និងកសាងភាពធន់រឹងមាំ និងអភិវឌ្ឍប្រកបដោយចីរភាព។

ប្រធានបទនេះបានគូសបញ្ជាក់ពីសារៈសំខាន់លើការលើកកម្ពស់ និងបន្តជំរុញការអនុវត្តគោលនយោបាយពង្រឹងសមភាពយេនឌ័ររបស់រាជរដ្ឋាភិបាល ដែលបានចាត់ទុកស្ត្រីជាឆ្អឹងខ្នង នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងការបញ្ជ្រាបយេនឌ័រជាអន្តរវិស័យក្នុងការធានានូវចីរភាព នៃសន្តិភាព និងកិច្ចអភិវឌ្ឍ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា នាឆ្នាំ២០៣០-២០៥០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០។ មានសន្តិភាព គឺមានអ្វីៗគ្រប់យ៉ាង។

ក្រសួងកិច្ចការនារី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះប្រមុខរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានគាំទ្រ និងចូលរួមយ៉ាងសកម្មបង្កលក្ខណៈឱ្យស្ត្រី ពង្រីកសក្តានុពលរបស់ខ្លួន ក្នុងកិច្ចការពារ និងបន្តស្តារសេដ្ឋកិច្ចឡើងវិញ ព្រមទាំងកសាងប្រទេសជាតិលើគ្រប់វិស័យ៕

# សូមក្រាបបង្គំទូលថ្វាយ សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល




ក្នុងឱកាសអបអរសាទរខួបលើកទី ១១២ ទិវាអន្តរជាតិនារី ៨ មីនា  ឆ្នាំ២០២៣ ខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតលំឱនកាយថ្វាយព្រះសព្ទសាធុការពរ សិរីមង្គល វបុលសុខ មហាប្រសើរ សូមសម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈ ដ៏ខ្ពង់ខ្ពស់បំផុត ព្រះប្រកបដោយព្រះរាជសុខុមាលភាពល្អបរិបូរណ៍ ព្រះកាយមាំមួន ព្រះទីឃាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីទ្រទ់គង់ជាម្លប់ដ៏ត្រជាក់ត្រៀមក្សាន្ត សម្រាប់ប្រជានុរាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា អស់កាលដ៏យូរអង្វែងតរៀងទៅ។

សូមក្រាបបង្គំទូលថ្វាយពី

ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងកិច្ចការនារី

# ព្រះរាជសារ

## សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
## ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
## ក្នុងឱកាសអបអរសាទរ ខួបលើកទី ១១២
## ទិវាអន្តរជាតិ នារី ៨មីនា ឆ្នាំ២០២៣

៚៚៚☆៛៛៛

- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ!
- បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា និងជាទីនឹករឭកដ៏ជ្រាលជ្រៅបំផុត !

នាឱកាសដ៏ល្អវិសេសវិសាលនៃខួបលើកទី ១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ នេះ ក្នុង **ព្រះបរមនាម ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និងខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង សូមថ្វាយនូវក្តីគោរពសក្ការៈ សម្តេចព្រះមហាសង្ឃរាជ ព្រះរាជាគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជម្រាបសួរសុខទុក្ខ ព្រមទាំងសូមផ្ញើក្តីនឹករឭក ដល់បងប្អូន កូនចៅ ចៅទួតទាំងអស់ នៅទូទាំងប្រទេស ដែលជានិច្ចកាលតែងតែនឹករឭក គោរពស្រឡាញ់ ផ្តល់នូវក្តីស្វាមីភ័ក្ត និងក្តីកតញ្ញូ ដ៏ជ្រាលជ្រៅថ្វាយ**ព្រះករុណា ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងរូបខ្ញុំព្រះករុណាផ្ទាល់ ដែលកាយវិការដ៏វិសេសវិសាលនេះ ធ្វើឱ្យខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ ចងចាំ និងគោរពស្រឡាញ់ មិនអាចបំភ្លេចបាន។

ក្នុងទិវាដ៏ថ្លៃថ្លានេះ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមសម្តែងនូវការកោតសរសើរ និងសូមគាំទ្រការលើកយកប្រធានបទ «**ស្ត្រីរួមគ្នា រក្សាសុខសន្តិភាព ដើម្បីកច្ចអនាគតល្អ ក្នុងយុគសម័យឌីជីថល**» គឺពិតជាមានសារៈសំខាន់ ដែលជាប្រធានបទឆ្លើយតបនឹងបរិបទបច្ចុប្បន្ន ក្នុងគោលបំណងបន្ទរំលេចពីតម្លៃនៃការចូលរួមរបស់ស្ត្រីដែលមិនអាចកាត់ថ្លៃបាន ក្នុងការថែរក្សាសុខសន្តិភាព ក៏ដូចជាកំពុងចូលរួមយ៉ាងសកម្មក្នុងការពន្លឿនកិច្ចអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសនៅក្នុងយុគសម័យឌីជីថលនេះ។

ព្រះរាជាណាចក្រកម្ពុជា មានសុខសន្តិភាពពេញលេញ អាស្រ័យ «**គោលនយោបាយឈ្នះ-ឈ្នះ**» ដែលបានផ្តួចផ្តើមដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ សុខសន្តិភាព ពិតជាមានសារៈសំខាន់ណាស់ ដែលធ្វើឱ្យប្រជារាស្ត្រ ជាកូនចៅ ចៅទួត

បានរស់នៅជាមួយភាពសុខដុមរមនា គ្រប់ជាតិសាសន៍ គ្មានការរើសអើង និងទទួលបានសិទ្ធិពេញលេញ ក្នុងការគោរពប្រតិបត្តិជំនឿ សាសនា និងទំនៀមទម្លាប់ប្រពៃណីដោយសេរី និងទទួលបាននូវកិច្ចគាំពារសង្គមដ៏ទូលំទូលាយ និងស្មើភាពគ្នា។

ក្រោមម្លប់នៃសន្តិភាព និងកិច្ចអភិវឌ្ឍ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ បានកត់សម្គាល់ឃើញថា ស្ត្រីកម្ពុជាជាកម្លាំងចលករ ដែលបានរួមចំណែកនៃកំណើនសេដ្ឋកិច្ចកន្លងមក ហើយបច្ចុប្បន្នស្ត្រីមានកាលានុវត្តភាពក្នុងការអនុវត្តសិទ្ធិ អភិវឌ្ឍចំណេះដឹង ជំនាញ និងបច្ចេកទេសដែលជាមូលដ្ឋានគ្រឹះក្នុងការចូលរួមប្រកួតប្រជែងប្រកបដោយសក្តានុពលក្នុងទីផ្សារសេដ្ឋកិច្ចថ្នាក់ជាតិ និងនៅក្នុងតំបន់ ហើយក៏ជាអ្នកទទួលបានភោគផលពីកិច្ចអភិវឌ្ឍលើគ្រប់វិស័យ ដែលធ្វើឱ្យជីវភាពរស់នៅរបស់ស្ត្រី និងគ្រួសារមានភាពប្រសើរឡើងរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងងាយរងគ្រោះ។ ស្ថានភាព ឋានៈ និងតួនាទីរបស់ស្ត្រីកម្ពុជាក៏ត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ រួមទាំងនៅក្នុងក្របខណ្ឌអភិបាលកិច្ច កិច្ចគាំពារសង្គម ការស្តារសេដ្ឋកិច្ច-សង្គមពីវិបត្តិកូវីដ-១៩ និងកិច្ចការនៅលើឆាកអន្តរជាតិ ។ ការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិត គឺជាគុណតម្លៃ ដើម្បីធានាថាប្រជាជនគ្រប់រូបមានសិទ្ធិ និងឱកាសពេញលេញក្នុងការទទួលបានជម្រើស ភាពជាតំណាង និងចូលរួមប្រកបដោយសក្តានុពល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ដែលបាននឹងកំពុងវិវត្តន៍ទៅជាសេដ្ឋកិច្ច និងសង្គមឌីជីថល ប្រកបដោយចីរភាព និងបរិយាប័ន្ន។ ក្នុងន័យនេះ ការបន្តរក្សាបាននូវសុខសន្តិភាព នៅតែជាអាទិភាពចម្បងទីមួយ និងមានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប ។

ព្រះរាជាណាចក្រកម្ពុជា ថែរក្សាបានយ៉ាងម៉ត់ចត់ នូវសុខសន្តិភាព ស្ថេរភាពនយោបាយ លទ្ធិប្រជាធិបតេយ្យ បានបន្តចាក់ឫសកាន់តែជ្រៅក្នុងសង្គមជាតិ ដំណើរការអភិវឌ្ឍសង្គម សេដ្ឋកិច្ច សម្រេចបានសមិទ្ធផលថ្មីៗប្រកបដោយមោទនភាព ទោះបីយើងត្រូវជួបប្រទះបញ្ហាប្រឈមយ៉ាងច្រើន ជាពិសេសការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ និងការវិវត្តិដ៏ស្មុគស្មាញនៃសភាពការណ៍នយោបាយ សេដ្ឋកិច្ចអន្តរជាតិ និងសង្គ្រាមអ៊ុយក្រែន--រុស្ស៊ីក្តី ។ ព្រមជាមួយនេះកិត្យានុភាពកម្ពុជាលើឆាកអន្តរជាតិ កាន់តែបានលើកកម្ពស់ស្របពេលដែលកម្ពុជាបានអនុវត្តតួនាទីជាប្រធានអាស៊ានប្តូរវេនប្រកបដោយជោគជ័យ ។

នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំ សូមសម្តែងការកោតសរសើរ និងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ចំពោះការយកចិត្តទុកដាក់អនុវត្តគោលនយោបាយ និងវិធានការ ផ្ការីកក្នុងយុទ្ធនាការចាក់វ៉ាក់សាំង ដែលធ្វើឱ្យកម្ពុជាបានកាត់បន្ថយហានិភ័យខ្ពស់ចំពោះប្រជាពលរដ្ឋអំពីការបាត់បង់ជីវិត ព្រមទាំងកម្មវិធីយុទ្ធសាស្ត្រដើម្បីស្តារសេដ្ឋកិច្ច

ក្រោយវិបត្តិកូវីដ១៩ ដែលនាំឱ្យសេដ្ឋកិច្ចកម្ពុជាក្រោកឈរឡើងវិញយ៉ាងឆាប់រហ័ស។ ទន្ទឹមនឹងនេះ ខ្ញុំសូមកោតសរសើរ និងអរគុណដល់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ដែលបានដឹកនាំកម្មវិធីមនុស្សធម៌ និងសកម្មភាពនៅក្នុងវិស័យសុខាភិបាល ដែលបានរួមចំណែកយ៉ាងសំខាន់ ក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋ ក្នុងគោលបំណងមិនទុកនរណាម្នាក់ឱ្យនៅឯកោ ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងអំណរព្រះគុណ សម្តេចព្រះមហាសង្ឃរាជ ព្រះរាជាគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមអរគុណដ៏ជ្រាលជ្រៅដល់បងប្អូនជនរួមជាតិ មន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិទាំងអស់ដែលបាននឹងបន្តខិតខំប្រឹងប្រែងចូលរួមអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដើម្បីរួមគ្នាកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យ កម្ពុជាប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។

ខ្ញុំ សូមសរសើរ និងគាំទ្រក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលបាននឹងកំពុងខិតខំប្រឹងប្រែងអនុវត្តភារកិច្ចដ៏ថ្លៃថ្លា ដើម្បីស្ត្រីបានទទួលនូវកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ ព្រមទាំងរក្សាបាននូវតម្លៃ និងភាពថ្លៃថ្នូរ តាមរយៈការកែប្រែឥរិយាបថសង្គមឱ្យទទួលស្គាល់ និងចាត់ទុកស្ត្រីជាដៃគូដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារ និងសង្គមដោយជួយជំរុញការកសាង និងអភិវឌ្ឍសមត្ថភាពស្ត្រី ក៏ដូចជាការផ្តល់ឱកាសឱ្យស្ត្រីចូលរួមប្រកបដោយសមធម៌ សមភាព ក្នុងគ្រប់ការងារ និងក្នុងគ្រប់វិស័យ។ ជាមួយគ្នានេះ ខ្ញុំ សូមអំពាវនាវ និងលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាល និងដៃគូរពាក់ព័ន្ធបន្តអនុវត្តការងារនេះ និងបន្តយកចិត្តទុកដាក់ ព្រមទាំងបង្កឱកាសឱ្យស្ត្រីនិងក្មេងស្រីបានចូលរួម និងទទួលបាននូវអត្ថប្រយោជន៍ក្នុងយុគសម័យឌីជីថល ដើម្បីវិបុលភាព និងសេចក្តីសុខចម្រើនរបស់ជនរួមជាតិយើង ។

ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមប្រសិទ្ធិពរជ័យ សិរីមង្គលមហាប្រសើរជូនចំពោះថ្នាក់ដឹកនាំ នីតិបញ្ញត្តិ នីតិប្រតិបត្តិនិងតុលាការ មន្ត្រីរាជការទាំងអស់ គ្រប់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន ព្រមទាំងបងប្អូនរួមជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងនារីទូទាំងសកលលោក សូមបានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ សូមអរគុណ**




## សុន្ទរកថា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបើកកិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី ២ ក្រោមប្រធានបទ *«ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និង ភាន់តែរឹងមាំ ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន»*

### រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២




- ***ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ាន និងប្រទេសដៃគូ !***
- ***ឯកឧត្តមអគ្គលេខាធិការអាស៊ាន !***
- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សក្រៃលែង ដោយបានទទួលស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង ភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ ដោយផ្ទាល់ផង និងតាមរយៈប្រព័ន្ធវីដេអូ ផង ។

ខ្ញុំសូមរំលឹកថា កិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី ១ ត្រូវបានរៀបចំឡើងកាលពីឆ្នាំ២០២០ ប្រកបដោយភាពជោគជ័យ ដោយថ្នាក់ដឹកនាំ នៃបណ្តាប្រទេសអាស៊ានបានទទួលស្គាល់ និងឱ្យតម្លៃខ្ពស់ចំពោះការដាក់បញ្ចូលការលើកកម្ពស់តួនាទីរបស់ស្ត្រីទៅក្នុងចំណុចស្នូល នៃកិច្ចខិតខំប្រឹងប្រែង សម្រាប់ការស្តារសង្គម-សេដ្ឋកិច្ចពីវិបត្តិនៃជំងឺកូវីដ-១៩ ប្រកបដោយចីរភាព និង ភាពគ្រប់ជ្រុងជ្រោយ ។ ទន្ទឹមគ្នានេះ ក៏មានការទទួលស្គាល់ និងការពិភាក្សាអំពីអាទិភាពនានា ជុំវិញការពង្រឹងតួនាទីរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និង ឌីជីថល ការឆ្លើយតបទៅនឹងកិច្ចគាំពារសង្គម ការថែទាំគ្រួសារ និង




ប្រាក់ឈ្នួលទាប ព្រមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសង្គម ដើម្បីឆ្លើយតបនឹងសមភាពយេនឌ័រ និងសុខុមាលភាពរបស់ស្ត្រី ។

ឈរលើសមិទ្ធផលដ៏ប្រពៃនេះ កម្ពុជាពិតជាមានកិត្តិយស ដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២នាពេលនេះក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២។ កម្ពុជា បានកំណត់ប្រធានបទ **«ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន»** ដើម្បីជំរុញកិច្ចសហការ និងការប្តេជ្ញាចិត្តរួមគ្នា ក្នុងការលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី ឱ្យក្លាយជាកម្លាំងចលករគន្លឹះប្រកបដោយចីរភាព និងកាន់តែរឹងមាំក្នុងការស្តារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឡើងវិញ ឆ្ពោះទៅរកការកសាងអនាគត និងវិបុលភាពរួមមួយ ។

***- ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

អាស៊ាន គឺជាតំបន់ ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស ជាពិសេសដោយសារការចូលរួមដ៏សកម្មរបស់ស្ត្រី ។ សេដ្ឋកិច្ចនៃបណ្តាប្រទេសក្នុងអាស៊ាន ពឹងផ្អែកខ្លាំង លើសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលដឹកនាំដោយស្ត្រី ។ ជាក់ស្តែង កម្ពុជាមានសហគ្រាសធុនមីក្រូ តូច និងមធ្យម រហូតដល់ទៅ ៩៨% នៃចំនួនសហគ្រាសសរុប ដែលបានចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិ ប្រមាណ ៥៨% និង បានផ្តល់ការងារប្រមាណ ៧៣% នៃការងារសរុប ។ ក្នុងនោះស្ត្រី គឺជាអ្នកបង្កើត និង គ្រប់គ្រងប្រមាណ ៦១% នៃចំនួនសរុប នៃសហគ្រាសធុនមីក្រូ តូច និង មធ្យម ។ ការណ៍នេះ បានធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាកំណត់ និងជំរុញការលើកតម្កើង **ស្ត្រីជាឆ្អឹងខ្នង នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ** តាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និង ការលើកកម្ពស់ តួនាទីរបស់ស្ត្រីនៅក្នុងកិច្ចអភិវឌ្ឍនៅគ្រប់វិស័យ និង គ្រប់កម្រិត ។

ក្នុងក្របខណ្ឌអាស៊ាន ទាំងបច្ចុប្បន្ន និង ទៅអនាគត ស្ត្រី នឹងបន្តដើរតួនាទីជាតួអង្គដ៏សំខាន់ ជាពិសេសក្នុងការស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចអាស៊ានឡើងវិញប្រកបដោយចីរភាព បរិយាបន្ន និង ភាពរឹងមាំ ។ ការណ៍នេះទាមទារឱ្យមានការរួមសាមគ្គី និងសហការគ្នាបង្កើតប្រព័ន្ធអេកូឡូស៊ី ដែលអំណោយផលដល់ការរីកលូតលាស់របស់សហគ្រិនស្ត្រី និងការចូលរួមសហការដោះស្រាយបញ្ហាប្រឈមផ្សេងៗ ។ ជាក់ស្តែង សហគ្រិនភាពរបស់ស្ត្រីនៅក្នុងតំបន់អាស៊ាន បាននិងកំពុងប្រឈមនឹងឧបសគ្គជាច្រើនក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងសហគ្រាស ជាពិសេសនៅតាមតំបន់ទីជនបទ ។ ម្យ៉ាងវិញទៀត ស្ត្រីភាគច្រើនចាប់ផ្តើមដំណើរការអាជីវកម្មនៅកម្រិតមីក្រូ កម្រិតតូចៗ និងស្ថិតនៅក្រៅប្រព័ន្ធ ដោយភាគច្រើនលើសលប់មិនទាន់បានចុះបញ្ជីអាជីវកម្មផ្លូវការនៅឡើយ ដែលអាចបង្កឱ្យមាន




ការលំបាកដល់រដ្ឋាភិបាល ក្នុងការកំណត់ និងផ្តល់ការគាំទ្រតាមការចាំបាច់ ។

ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ ក៏ដូចជាបំផុសសក្តានុពលសហគ្រិនស្ត្រី និងបង្កភាពងាយស្រួលក្នុងការចាប់យកនូវកាលានុវត្តភាព និងសក្តានុពលថ្មីៗនានា យើងគួរពិនិត្យ និងផ្តល់ការយកចិត្តទុកដាក់លើកិច្ចការមួយចំនួន ដូចខាងក្រោម៖

**ទី១.** រៀបចំប្រព័ន្ធអេកូឡូស៊ី (Ecosystem) ដែលឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម និង សហគ្រិនស្ត្រី រួមទាំងការកែលម្អនូវក្របខណ្ឌគតិយុត្ត និង ផ្នត់គំនិតសង្គមដែលរារាំងដល់សក្តានុពលរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច ។

**ទី២.** ផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្ស តាមរយៈកម្មវិធីលើកកម្ពស់ ជំនាញ (Upskilling) និង បណ្តុះបណ្តាលជំនាញថ្មី (Re-skilling) ដល់ស្ត្រី និងក្មេងស្រី រួមទាំង កម្មវិធីអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា (STEM) ។

**ទី៣.** លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និង ឌីជីថលសម្រាប់ស្ត្រី និងក្មេងស្រី តាមរយៈការផ្តល់នូវចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងឌីជីថល (Financial and Digital Literacy) និងការសម្រួលលទ្ធភាពទទួលឥណទានទីផ្សារ និងព័ត៌មានក្នុងការចាប់ផ្តើម និង អភិវឌ្ឍអាជីវកម្ម ។

**ទី៤.** ពង្រីកវិសាលភាពគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម វិធានការគោលនយោបាយនានាផ្នែកគាំពារសុខុមាលភាពគ្រួសារ និង ការឆ្លើយតបលើការងារថែទាំគ្រួសារ និង ការងារផ្ទះរបស់ស្ត្រី ព្រមទាំងការវិនិយោគសាធារណៈលើវិស័យសេវាថែទាំ និង សុខុមាលភាពសង្គម។

***- ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

កិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី២ ដែលមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំកំពូល នៃបណ្តាប្រទេសអាស៊ាន និង ប្រទេសជាដៃគូ គឺជាសក្ខីភាព ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តដ៏មុតមាំ ក្នុងការរួមសាមគ្គី និងសហការគ្នាលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី ។ ជាក់ស្តែង នៅក្នុងកិច្ចប្រជុំនាថ្ងៃនេះ យើងនឹងពិភាក្សា និងផ្តល់យោបល់លើការរៀបចំ សេចក្តីថ្លែងការណ៍ ស្តីពីការកសាងអនាគតប្រកបដោយចីរភាព បរិយាប័ន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីនៅក្នុងអាស៊ាន។ ខ្ញុំសង្ឃឹមថា ថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ាន និងប្រទេសជាដៃគូទាំងអស់ នឹងផ្តល់ការគាំទ្រដល់សេចក្តីថ្លែងការណ៍នេះ ។

ជាកិច្ចបញ្ចប់ ខ្ញុំសូមជូនពរឱ្យកិច្ចប្រជុំកំពូលនេះ ដំណើរការទៅដោយរលូន និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង ភ្ញៀវកិត្តិយសទាំងអស់ ប្រកបដោយសុខភាពល្អ និង សម្រេចជោគជ័យគ្រប់ភារកិច្ច ។

ខ្ញុំសូមប្រកាសបើកជាផ្លូវការនូវ កិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី ២ ចាប់ពីពេលនេះតទៅ ៕

# សម្តេចតេជោ ហ៊ុន សែន និងសម្តេចកត្តាព្រឹទ្ធបណ្ឌិតអញ្ជើញចុះសួរសុខទុក្ខដល់កុមារី/យុវតី រងគ្រោះនៅមជ្ឈមណ្ឌល បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងស្ដារនីតិសម្បទាយុវនារី អាហ្វេស៊ីប (AFESIP) ទំនុំឱ



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា បានអញ្ជើញចុះសួរសុខទុក្ខដល់កុមារី/យុវតីរងគ្រោះនៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងស្ដារនីតិសម្បទាយុវនារី អាហ្វេស៊ីប (AFESIP) ទំនុំឱ កាលពីព្រឹកថ្ងៃអាទិត្យ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ស្ថិតនៅសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ នៅថ្ងៃនោះ ក្រៅតែពីការសួរសុខទុក្ខដោយផ្ទាល់នោះ **សម្តេចតេជោ ហ៊ុន សែន** និង **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ក៏បានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារមួយខ្នងកម្ពស់ ៣ជាន់ស្មើនឹង ៤០បន្ទប់ ដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចទាំងទ្វេ** នៅក្នុងអង្គការនេះផងដែរ។

**សម្តេចតេជោ ហ៊ុន សែន** និង**សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ពិតជារីករាយដែលបានអញ្ជើញមកជួបជាមួយកុមារី និងយុវតី ប្រកបដោយក្តីក្តុកក្តួល ចំពោះបញ្ហាដែលពួកគេជួបប្រទះពេលកន្លងមក។ **សម្តេចតេជោ** និង **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** មានមោទនភាពចំពោះការជួយជ្រោមជ្រែង ដើម្បីជាប្រយោជន៍សម្រាប់កុមារី និងយុវតីរងគ្រោះនៅអង្គការអាហ្វេស៊ីប។ **សម្តេចតេជោ** ក៏បានអំពាវនាវដល់បុរសៗទាំងឡាយត្រូវបញ្ឈប់ការធ្វើសកម្មភាព ដែលមិនមានសីលធម៌ជាមនុស្សនៅក្នុងសង្គម។ **សម្តេចតេជោ** ក៏បានអំពាវនាវឱ្យរួមគ្នាប្រយុទ្ធប្រឆាំងការរំលោភបំពាន និងការជួញដូរផ្លូវភេទសម្រាប់ក្មេងស្រីតទៅទៀត។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់សប្បុរសជននានា ដែលបានផ្តល់ការឧបត្ថម្ភដល់អង្គការអាហ្វេស៊ីប ព្រោះការឧបត្ថម្ភនេះ គឺជាការឧបត្ថម្ភចំកន្លែងដែលគួរឧបត្ថម្ភ សម្រាប់ជួយកុមារដែលរងគ្រោះទាំងអស់នេះ។ **សម្តេចតេជោ ហ៊ុន សែន** ប្រកាសដាក់ចេញគោលការណ៍ឱ្យកុមារីនៅអង្គការអាហ្វេស៊ីប ត្រូវតែបានបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា ហើយ**សម្តេច**ក៏បានប្រកាសធានាដល់ការសិក្សារបស់ក្មេងស្រីរងគ្រោះនៅអង្គការអាហ្វេស៊ីបនេះ ដោយផ្តល់ជាអាហារូបករណ៍សិក្សារហូតថ្នាក់ឧត្តមសិក្សា។ **សម្តេច** ក៏រីករាយផងដែរចំពោះកុមារីរងគ្រោះនៅអង្គការអាហ្វេស៊ីប ដែលបានប្រឡងជាប់ចូលក្របខណ្ឌនគរបាលជាតិ និងយោធានាពេលកន្លងទៅ។

នៅថ្ងៃនេះ **សម្តេចតេជោ ហ៊ុន សែន** បានសម្រេច



បង្កើនការឧបត្ថម្ភថវិកាដល់អង្គការអាហ្វេស៊ីបពី ១០លានរៀល ទៅ ២០លានរៀល សម្រាប់ចំណាយលើការហូបចុក។ ការតម្លើងនេះចាប់ផ្តើមពីខែមករា ឆ្នាំ២០២៣តទៅ និងបន្តផ្តល់ប្រាក់១០ម៉ឺនរៀលដល់ក្មេងស្រីនៅអង្គការអាហ្វេស៊ីប។ **សម្តេច** ក៏បានសម្រេចឧបត្ថម្ភដល់អង្គការអាហ្វេស៊ីបចំនួន ៥ម៉ឺនដុល្លារក្នុងមួយឆ្នាំ ដើម្បីដោះស្រាយបញ្ហាតម្រូវការផ្សេងៗទៀតផង។

នៅថ្ងៃនេះ **សម្តេចតេជោ ហ៊ុន សែន** ក៏បានឯកភាពទទួលសំណើ កុំឱ្យនាំយកកុមារីរងគ្រោះដោយការរំលោភបំពានអាយុក្រោម ៥ឆ្នាំឡើងតុលាការ ប្រឈមជាមួយជនល្មើសនោះទេ។ សំណើនេះធ្វើឡើងតាមការស្នើរបស់លោកស្រី **ម៉ម សុម៉ាលី** នាយកអង្គការអាហ្វេស៊ីប។

មុននឹងបញ្ចប់ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានជូនពរដល់ចៅៗ ក្មួយៗទាំងអស់ជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងសំណាងល្អក្នុងជីវិតនៅពេលអនាគត៕ ***ដកស្រង់ពីហ្វេសប៊ុកផេកសម្តេចតេជោ***



# សកម្មភាពកាកបាទក្រហមកម្ពុជា







ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០២២ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា អញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំឆ្នាំគណៈកម្មាធិការកណ្តាល ដោយមានការអញ្ជើញចូលរួមពី សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឱ្ត គង់ សំអុល អនុប្រធានអចិន្ត្រៃយ៍ លោកជំទាវ ឯកឧត្តម អនុប្រធាន អគ្គហេរញ្ញិក សមាជិកគណៈកម្មាធិការកណ្តាល និងក្រុមប្រតិបត្តិ សរុបចំនួន ២៦រូប។





នៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០២២ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងបំពាក់គ្រឿងឥស្សរិយយសជូននិវត្តន៍ជន-មន្ត្រីកាកបាទក្រហមកម្ពុជា ដែលធ្លាប់បានបម្រើការងារមនុស្សធម៌យ៉ាងសកម្មនាពេលកន្លងមក។



# លទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងកិច្ចការនារី

**ស្រង់ពីរបាយការណ៍សង្ខេបលទ្ធផល សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារសម្រាប់ឆ្នាំ២០២៣ របស់ក្រសួងកិច្ចការនារី**



**លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកផែនការសកម្មភាពការងារឆ្នាំ២០២៣ របស់ក្រសួងកិច្ចការនារី**

## សេចក្តីផ្តើម៖

ក្រោមម្លប់នៃសុខសន្តិភាព និងការអភិវឌ្ឍ ស្ត្រីកម្ពុជាជាកម្លាំងចលករ ដោយបានរួមចំណែកនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកន្លងមក ហើយស្ត្រីមានកាលានុវត្ត-ភាព នៅក្នុងការទទួលបានសិទ្ធិ និងជម្រើស ក្នុងការអភិវឌ្ឍចំណេះដឹង និងជំនាញបច្ចេកទេសដែលជាមូលដ្ឋាន ក្នុងការចូលរួមប្រកួតប្រជែងប្រកបដោយសក្តានុពល នៅក្នុងទីផ្សារសេដ្ឋកិច្ចថ្នាក់ជាតិ និងនៅក្នុងតំបន់ ហើយក៏ជាអ្នកទទួលបានភាគផលពីកិច្ចអភិវឌ្ឍលើគ្រប់វិស័យ ដែលធ្វើឱ្យជីវភាពរស់នៅមានភាពប្រសើរ បានកាត់បន្ថយភាពងាយរងគ្រោះ និងរួមចំណែកយ៉ាងសំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្រ ។

នៅឆ្នាំ២០២២នេះ ទោះជំងឺកូវីដ-១៩ មិនទាន់ទៅណាឆ្ងាយ ប៉ុន្តែប្រជាពលរដ្ឋទូទាំងប្រទេសមានអារម្មណ៍ធូរស្រាលច្រើន ហើយបានចាប់ផ្តើមដំណើរការការងារ ការរស់នៅ និងការប្រកបមុខរបរចិញ្ចឹមជីវិតដូចធម្មតាឡើងវិញ។ ទាំងនេះក៏អាស្រ័យដោយកម្ពុជា ទទួលបានជោគជ័យតាមរយៈការចាត់វិធានការគោលនយោបាយផ្នែករដ្ឋបាល សេដ្ឋកិច្ច និងសង្គមជាបន្តបន្ទាប់ និងជាពិសេសការកៀរគរកម្លាំងសរុបរបស់ជាតិ លើយុទ្ធនាការជាតិចាក់វ៉ាក់សាំង ដែលបង្កើតបានភាពស៊ាំសហគមន៍ដ៏រឹងមាំមួយទូទាំងប្រទេស ។

នៅក្នុងបរិបទសង្គម កំពុងស្ថិតនៅក្នុងស្ថានភាពស្តារនិងជំរុញសេដ្ឋកិច្ច-សង្គម ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ក្រសួងកិច្ចការនារី ក៏ដូចជាបណ្តាស្ថាប័នផ្សេងៗ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងនៅថ្នាក់ជាតិ និងក្រោមជាតិ បានខិតខំប្រឹងប្រែង ជំនះឧបសគ្គ និងបន្តដំណើរការស្ថាប័ន និងបំពេញមុខងារលើវិស័យកិច្ចការនារី និងការបញ្ជ្រាបយេនឌ័របានដោយរលូន និងទទួលបានលទ្ធផលគួរជាទីកត់សម្គាល់ ។ នៅក្នុងន័យនេះ ក្រសួងនិងមន្ទីរកិច្ចការនារី បានពង្រឹងសមត្ថភាពផ្នែកបច្ចេកវិទ្យាឌីជីថលផង ស្វែងយល់ពីតម្រូវការថ្មីៗ ដែលកើតចេញពីវិបត្តិផង ដើម្បីស្វែងរកវិធីឆ្លើយតប និងបានបន្តចូលរួមយ៉ាងសកម្ម ក្នុងការរួមចំណែកអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងមុខងារ និងសេវាសាធារណៈលើការលើកកម្ពស់ស្ថានភាព ឋានៈ តួនាទីជូនស្ត្រី និងក្មេងស្រី ប្រកបដោយបរិយាប័ន្ន ។

## សមិទ្ធផលគន្លឹះៗ ដែលក្រសួងនិងមន្ទីរកិច្ចការនារី សម្រេចបាន ក្នុងឆ្នាំ២០២២៖

### ១. ការងារបញ្ជ្រាបយេនឌ័រតាមវិស័យ

- បានគាំទ្របច្ចេកទេសដល់ក្រសួង-ស្ថាប័ន ក្នុងការអភិវឌ្ឍសមត្ថភាព ស្តីពីការបញ្ជ្រាបយេនឌ័រចំនួន៣ និងក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រ ក្រសួង-ស្ថាប័ន ចំនួន ២ ។




**លោកជំទាវខេង សំវ៉ាដា រដ្ឋលេខាធិការប្រចាំការ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី និងលោកជំទាវថ្នាក់ដឹកនាំក្រសួងកិច្ចការនារី ជូនបាច់ផ្កា លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងអង្គពិធី**

- កែសម្រួលបញ្ចប់សេចក្តីព្រាងចុងក្រោយ គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ តាមរយៈធាតុចូលពីក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ និងគ្រោងរាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ ណែនាំ និងសម្រេច ។
- បានអនុវត្តគម្រោងលើកកម្ពស់ការបញ្ជ្រាបយេនឌ័រក្នុងប្រព័ន្ធស្ថិតិយេនឌ័រ លើវិស័យការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ តាមរយៈការពង្រឹងសមត្ថភាព និងរៀបចំឯកសារណែនាំ ក្នុងការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងទិន្នន័យនិងស្ថិតយេនឌ័រ ។
- បានចូលរួមបញ្ជ្រាបយេនឌ័រនៅក្នុងសេចក្តីព្រាងផែនការអនុវត្ត នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, សេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឯកសារណែនាំសម្រាប់អ្នកសម្របសម្រួល នៃសាលាជាតិរដ្ឋបាលមូលដ្ឋាន សេចក្តី ព្រាងឯកសារ-ស ស្តីពីបរិស្ថាន និងឯកសារកម្មវិធីសិក្សា ថ្នាក់ទី១ ដល់ទី១២ ។
- បានរៀបចំផែនទីបង្ហាញផ្លូវស្តីពីការរៀបចំថវិកាឆ្លើយតបយេនឌ័រ និងបានចូលរួមជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសិក្សាអំពីលទ្ធភាពនានា ក្នុងការអនុវត្តថវិកាឆ្លើយតបនឹងយេនឌ័រ ក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## ២. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី បានរៀបចំក្របខណ្ឌភាពជាដៃគូ (MOU) ជាមួយស្ថាប័នបណ្តុះបណ្តាល និងកៀរគរដៃគូអភិវឌ្ឍន៍គាំទ្រដល់គម្រោងសម្រាប់អនុវត្តចាប់ពីឆ្នាំ២០២៣ និង ឆ្នាំបន្ទាប់ ។
- បានអនុវត្តកម្មវិធីលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុសម្រាប់ស្ត្រីនិងសហគ្រិនស្ត្រី ក្នុងភាពជាដៃគូជាមួយធនាគារជាតិនៃកម្ពុជា (NBC) សម្រាប់ខេត្តគោលដៅចំនួន៩ ក្នុងការពង្រឹងសមត្ថភាពដល់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី លើផ្នែកចំណេះដឹងហិរញ្ញវត្ថុ និងឌីជីថល ។
- បានធ្វើការសិក្សាអំពីផលប៉ះពាល់យេនឌ័រ ក្នុងបរិបទកូវីដ-១៩ លើស្ត្រីជាម្ចាស់ ឬអ្នកគ្រប់គ្រងសហគ្រាសខ្នាតមីក្រូ តូចនិងមធ្យម (MSMEs) ដើម្បីកំណត់សេចក្តីស្នើគោលនយោបាយគាំទ្រជាក់លាក់ដល់សហគ្រិនភាពស្ត្រី ក្រោយបរិការណ៍ជំងឺកូវីដ-១៩ ។
- បានធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងរបាយការណ៍ អំពីមេរៀនបទពិសោធន៍ដែលឆ្លើយតបនឹងការងារថៃទាំគ្មានប្រាក់កម្រៃ និងសេដ្ឋកិច្ចដែលគិតគូរលើសុខុមាលភាព (Care Economy) នៅកម្ពុជា និងបានរៀបចំផែនការសកម្មភាពឆ្លើយតបតាមវិស័យ ព្រមទាំងកញ្ចប់កម្មវិធីផ្សព្វផ្សាយអប់រំ ដើម្បីបង្កើនការយល់ដឹងនិងគាំទ្រជាសាធារណៈ ។



**លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ថតរូបអនុស្សាវរីយ៍ជាមួយលោកជំទាវថ្នាក់ដឹកនាំក្រសួងស្ថាប័ន**

• បានចាប់ផ្តើមអនុវត្តកម្មវិធីពង្រឹងសមត្ថភាព និងធ្វើទំនើបកម្មមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅខេត្តចំនួន៤ លើការងារលើកកម្ពស់ចំណេះដឹងឌីជីថល ហិរញ្ញវត្ថុ ធុរកិច្ច និងការលើកកម្ពស់សេដ្ឋកិច្ចស្ត្រី ដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។

• តាមរយៈគម្រោងលើកកម្ពស់សេដ្ឋកិច្ចស្ត្រី និងសហគមន៍នៅខេត្តគោលដៅចំនួន៤ ទទួលបានកម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងជំនាញផលិត និងរបៀបក្នុងការប្រើប្រាស់បច្ចេកវិទ្យា សម្រាប់ការពង្រីកទីផ្សារផលិតផលសហគមន៍ ។

•មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តទាំង១៤ និងមន្ទីរកិច្ចការនារីរាជធានី-ខេត្ត បានបណ្តុះបណ្តាលដល់សិស្សបោះបង់ការសិក្សា ស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ជនជាតិដើមភាគតិច ស្ត្រីរងគ្រោះដោយអំពើហិង្សា និងទណ្ឌិតបានចំនួន ៣.០៨៧នាក់ ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកាត់ដេរ អ៊ុតសក់ សំអាងកាយ កែសម្ផស្ស និងតម្បាញ។

• នៅក្នុងព្រឹត្តការណ៍អមកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ ក្រសួងបានរៀបចំវេទិកា និងពិធីប្រគល់ពានរង្វាន់សហគ្រិនស្ត្រីអាស៊ាន វេទិកាថ្នាក់ជាតិស្តីពីការលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រីនៅតំបន់អាស៊ាន តាមរយៈគោលនយោបាយគាំពារគ្រួសារ និងគាំពារសង្គម និងវេទិកាថ្នាក់ដឹកនាំស្ត្រីអាស៊ាន-អូស្ត្រាលី ដើម្បីលើកកម្ពស់សហគ្រិនភាពស្ត្រីអាស៊ាន និងអូស្ត្រាលី ។

### ៣.កិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី និងទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ

• ក្រុមការងារឆ្លើយតបជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបាននិងកំពុងដំណើរការនៅខេត្ត ០៩ និងក្នុងស្រុកគោលដៅចំនួន៣៩ ។ កន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅមន្ទីរពេទ្យខេត្ត ចំនួន ០៤ បានដំណើរការ និងគ្រោងបង្កើតក្នុងខេត្តចំនួន ០២ទៀត ។

• បានអភិវឌ្ឍគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តិ សម្រាប់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងអ្នកផ្តល់សេវាឆ្លើយតបជូនជនរងគ្រោះក្នុងការអនុវត្តមុខងាររបស់ខ្លួន ។

• បានពង្រឹងសមត្ថភាពមន្ត្រីអ្នកផ្តល់សេវានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីជំនាញទាក់ទងនឹងការផ្តល់សេវាជូនស្ត្រី និងក្មេងស្រីជនរងគ្រោះ។

• បានផ្តល់សេវាឆ្លើយតបដោយផ្ទាល់ និងសម្របសម្រួលបញ្ជូនជនរងគ្រោះទៅរកសេវាពាក់ព័ន្ធចំនួន ៥៩៥ករណី (ប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្ត និងតាមអនឡាញ) ។

• រៀបចំយុទ្ធនាការ ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្រោមប្រធានបទរួមគ្នាបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ដោយមានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

• ក្រុមការងារត្រួតពិនិត្យតាមដានការអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី ត្រូវបានបង្កើតឡើង ដោយមានសមាសភាពពីតំណាងក្រសួងកិច្ចការនារី ក្រសួងព័ត៌មាន ក្លឹបអ្នកកាសែត គ្រឹះស្ថានអប់រំ ស្ថានីយវិទ្យុជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ និងបានដំណើរការជាប្រចាំ ក្នុងការពិនិត្យតាមដាន និងជំរុញការអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី ក្នុងប្រព័ន្ធសារព័ត៌មាន និងផ្សព្វផ្សាយនានា ។

**៤. ភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងវិស័យសាធារណៈ និងនយោបាយ**

• បានរៀបចំវេទិកាជាតិ ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច ក្នុងកិច្ចសហការជាមួយក្រុមប្រឹក្សាវប្បធម៌អាស៊ី ដោយមានការចូលរួមពីស្ត្រីជាអ្នកដឹកនាំស្ថាប័នជាតិ តំណាងរាស្ត្រ ក្រសួង-ស្ថាប័ន អង្គទូត អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ រដ្ឋបាលរាជធានីខេត្ត គ្រឹះស្ថានសិក្សា ក្រុមយុវជន និងតំណាងគណបក្សនយោបាយចំនួន១៧ គណបក្ស ដោយមានអ្នកចូលរួមផ្ទាល់ចំនួន១៩៩រូប និងតាមប្រព័ន្ធអនឡាញចំនួន ១.៧៥១រូប ។

• ក្រុមការងារបច្ចេកទេស ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច ដែលមានសមាជិកមកពីក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ បានរៀបចំកិច្ចប្រជុំជាប្រចាំ ដើម្បីពិនិត្យមើលលើវឌ្ឍនភាព ចែករំលែកមេរៀនបទពិសោធន៍ និងលើកទិសដៅការងារ ក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ ។

• បានដំណើរការកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រទី២ ឆ្នាំ២០២១-២០២២ ដែលជាកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជាសេរី រយៈពេល ១ឆ្នាំ សម្រាប់យុវជន ចំនួន២០នាក់ (ស្រី ១៤នាក់) មកពីក្រសួង-ស្ថាប័ន និងសាកលវិទ្យាល័យនានា ។



**៥. ការងារអប់រំ ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងជាសាធារណៈ**

• ក្រសួងនិងមន្ទីរកិច្ចការនារី បានរៀបចំនិងអនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹងពីសមភាពយេនឌ័រ ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ទប់ស្កាត់ការប្រើប្រាស់ និងចែកចាយគ្រឿងញៀន គ្រឿងស្រវឹង ការអប់រំមាតាបិតា និងអ្នកចិញ្ចឹមបីបាច់កុមារ សុខុមាលភាពសង្គម សុខភាពស្ត្រី ការកសាងទំនាក់ទំនងរវាងមាតា និងយុវតីទាក់ទងនឹងសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ជំងឺកាមរោគ និងមេរោគអេដស៍ យេនឌ័រ និងសុខភាពភ្នែក អាហារូបត្ថម្ភ សីលធម៌សង្គម យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការផ្លាស់ប្តូរឥរិយាបថ តាមរយៈព្រឹត្តិការណ៍សហគមន៍ កម្មវិធីផ្សព្វផ្សាយតាមបណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានា។

• យុទ្ធសាស្ត្រ និងឧបករណ៍ ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន កំពុងបន្តអនុវត្តនៅក្នុងខេត្តគោលដៅចំនួន០៩ និងធ្វើការប៉ាន់ប្រមាណតម្រូវការចំណាយសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ។

• បានអនុវត្តសាកល្បងផែនការសកម្មភាព ស្តីពីបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់នៅខេត្តរតនគិរី និងកំពុងពិនិត្យលទ្ធភាពពង្រីកនៅខេត្តផ្សេងទៀត ។

• គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានយកចិត្តទុកដាក់លើការលើកកម្ពស់សីលធម៌សង្គម តាមរយៈក្រសួង-ស្ថាប័ន បានផ្តល់បទអន្តរាគមន៍ និងកម្មវិធីអប់រំផ្សព្វផ្សាយនានា ដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិជនដែលមានពិការភាព និងសិទ្ធិដទៃទៀតក្នុងសង្គម ។

• យោងតាមការណែនាំរបស់**សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន** ដែលបានស្នើដល់ក្រសួងពាក់ព័ន្ធពិនិត្យឱ្យបានម៉ត់ចត់ និងមានវិធានការចំពោះរាល់អំពើនានា ជាពិសេសរូបភាពតាមប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនងសង្គម ជាសកម្មភាពមិនសមរម្យ និងប្រាសចាកសីលធម៌សង្គម ដែលតម្រូវឱ្យមានការអន្តរាគមន៍ជាចាំបាច់ និងភ្លាមៗពីស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋានគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានរៀបចំសេចក្តីព្រាងនីតិវិធីប្រតិបត្តិស្តង់ដា (SOP) ស្តីពីការឆ្លើយតបរបស់ក្រសួង-ស្ថាប័ន ក្នុងការលើកកម្ពស់សីលធម៌សង្គមតាមប្រព័ន្ធអនឡាញ និងបានឆ្លងយោបល់កម្រិតបច្ចេកទេសរួចរាល់ មុននឹងដាក់ជូនគណៈកម្មការពិនិត្យ និងសម្រេច ។

### ៦.ការអភិវឌ្ឍធនធានមនុស្ស និងប្រសិទ្ធភាពស្ថាប័ន៖

• បានបង្កើត និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការបន្ទប់បំបៅដោះកូន ដើម្បីជួយសម្រួលដល់មន្ត្រីរាជការ និងបុគ្គលិកនៅក្រសួងកិច្ចការនារី ដែលមានកូនតូចអាចបន្តបំបៅដោះកូនដោយទឹកដោះ នៅពេលដែលគាត់ត្រឡប់មកធ្វើការងារវិញ បន្ទាប់ពីសម្រាកលំហែមាតុភាព។

• បានបង្កើត និងអនុវត្តគោលការណ៍ណែនាំសម្រាប់ដំណើរការទារកដ្ឋានរបស់ក្រសួងកិច្ចការនារី ។

• ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងនិងមន្ទីរកិច្ចការនារី បានទទួលកម្មវិធីអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងភាពជាអ្នកដឹកនាំ ការបញ្ជ្រាបយេនឌ័រ ការទប់ស្កាត់អំពើហិង្សា ការលើកកម្ពស់សិទ្ធិជនមានពិការភាព ជាពិសេសសិទ្ធិស្ត្រី និងក្មេងស្រី ការស្វែងរកការគាំទ្រមតិ ការអភិវឌ្ឍសហគ្រិនភាពស្ត្រី ការគ្រប់គ្រងរដ្ឋបាល ផែនការឆ្លើយតបយេនឌ័រ ការធ្វើកំណែទម្រង់ថវិកា ការប្រើប្រាស់បច្ចេកវិទ្យា និងការរៀបចំកិច្ចប្រជុំតាមរយៈប្រព័ន្ធអនឡាញ និងស្ត្រី និងអាស៊ាន ។

• បានបន្តអភិវឌ្ឍសមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ លើចំណេះដឹងក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងពង្រីកដំណើរការប្រព័ន្ធបណ្តាញសង្គម និងគេហទំព័ររបស់ក្រសួងក្នុងការផ្តល់ព័ត៌មាន បង្កើនការយល់ដឹង និងការប្រមូលព័ត៌មានត្រឡប់ពីមហាជន ។

• ក្រសួងកិច្ចការនារី បានចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការបង្កើនប្រសិទ្ធភាពស្ថាប័ន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការគាំទ្រលើការអនុវត្តមុខងារដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ។

### ៧. កិច្ចសហការអន្តរជាតិ និងជាមួយដៃគូពាក់ព័ន្ធ

• ក្រសួងបានចូលរួម និងចែករំលែកបទពិសោធន៍ចំណុចឧត្តមានុវត្តន៍ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈព្រឹត្តិការណ៍អន្តរជាតិ និងក្នុងតំបន់ ដូចជានៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្ត្រីអាស៊ាន កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីតំបន់អាស៊ីប៉ាស៊ីហ្វិក កិច្ចប្រជុំ G20 កិច្ចប្រជុំរបស់ភ្នាក់ងារអង្គការសហប្រជាជាតិ អាស៊ាន និងថ្នាក់តំបន់នានា ។

• គិតត្រឹមឆ្នាំ២០២២នេះ ក្រសួងមានអនុស្សរណៈ និងកិច្ចព្រមព្រៀងផ្លូវការចំនួន ១៥ ដែលកំពុងមានសុពលភាព ជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិ និងវិស័យឯកជននានា ។

ជាមួយគ្នានេះ នៅពេលដែលកម្ពុជាជាប្រធានប្តូរវេនអាស៊ាន ក្រសួងកិច្ចការនារី ក៏បានចូលរួមក្នុងការដឹកនាំការសម្របសម្រួលរៀបចំព្រឹត្តិការណ៍ និងចូលរួមសម្រេចបានសមិទ្ធផលពាក់ព័ន្ធនឹងស្ត្រីសម្រាប់ថ្នាក់តំបន់ ក្នុងនោះរួមមាន៖ បានរៀបចំដោយជោគជ័យនូវកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ កាលពីខែតុលា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ និងដឹកនាំដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រួមទាំងព្រឹត្តិការណ៍ពាក់ព័ន្ធ ការរៀបចំសេចក្តីថ្លែងការណ៍ស្តីពីការបំផុសសហគ្រិនភាពស្ត្រីក្នុងអាស៊ាន និងផែនការសកម្មភាពថ្នាក់តំបន់ស្តីពីស្ត្រីសន្តិភាព និងសន្តិសុខ ដែលទទួលបានការអនុម័ត ដោយប្រមុខដឹកនាំអាស៊ាន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និងទី៤១ កាលពីខែវិច្ឆិកា ឆ្នាំ២០២២កន្លងមកនេះ។

ទន្ទឹមនឹងសមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ យើងក៏នៅមានបញ្ហាប្រឈមដែលសេសសល់ និងកើតមានថ្មីៗ ជាពិសេសក្នុងអំឡុង និងក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ក៏ដូចជាការប្រែប្រួលនានាផ្សេងទៀតនៅក្នុងសង្គម និងក្នុងយុគសម័យឌីជីថល ។

ក្នុងបរិការណ៍នេះ ក្រសួង និងមន្ទីរកិច្ចការនារី នឹងបន្តផ្តោតយកចិត្តទុកដាក់លើការអភិវឌ្ឍស្ថាប័ន និងពង្រីកវិសាលភាពការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥



ដឹកនាំសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ក្នុងការអនុវត្តផែនការសកម្មភាពជាតិ ស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងការចូលរួមនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព។

**ទិសដៅអាទិភាពសម្រាប់ឆ្នាំ២០២៣ សំខាន់ៗរបស់ក្រសួង និងមន្ទីរកិច្ចការនារី រួមមាន៖**

**ទី ១.** បន្ដជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងក្របខណ្ឌគោលនយោបាយ និងកម្មវិធីជាតិនានា រួមទាំងនៅក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្របខណ្ឌជាតិគាំពារសង្គម កម្មវិធីពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងសង្គមឌីជីថល និងការប្រែប្រួលអាកាសធាតុជាដើម។ នៅក្នុងនោះ ក្រសួងនឹងបន្តគាំទ្រដល់យន្តការបញ្ជ្រាបយេនឌ័រនៅតាមវិស័យ រួមទាំងផ្ដួចផ្ដើមលើការអនុវត្តថវិកាឆ្លើយតបយេនឌ័រ និងប្រព័ន្ធគ្រប់គ្រងស្ថិតិយេនឌ័រនៅតាមវិស័យ ។

**ទី ២.** បន្តលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី នៅក្នុងវិស័យសាធារណៈ ឯកជន និងនយោបាយ រួមទាំងពង្រីកកម្មវិធីភាពជាអ្នកដឹកនាំស្ត្រីក្នុងវិស័យសាធារណៈ និងក្នុងចំណោមក្រុមមនុស្សវ័យក្មេង។

**ទី ៣.** ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈអភិវឌ្ឍសហគ្រិនភាពស្ត្រី បង្កើនចំណេះដឹង និងជំនាញពាក់ព័ន្ធបច្ចេកវិទ្យាឌីជីថល សេដ្ឋកិច្ចបៃតង បរិយាបន្នហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដែលគិតគូរដល់សុខុមាលភាព។

**ទី ៤.** ទប់ស្កាត់អំពើហិង្សាគ្រប់រូបភាពលើស្ត្រី តាមរយៈការបន្តអនុវត្តផែនការសកម្មភាពជាតិ ស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ជាពិសេសការពង្រីក ការបង្កើតក្រុមការងារជាពហុវិស័យឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះនៅថ្នាក់ក្រោមជាតិ និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**ទី៥.** ធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពជាតិនេះ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំផែនការសកម្មភាពបន្តទៀត និងធ្វើការប៉ាន់ប្រមាណលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

**ទី៦.** លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមរយៈបន្តអនុវត្តកម្មវិធីមាតាបិតាភាព និងការអប់រំកូនតាមបែបវិជ្ជមាន និងពង្រីកវប្បធម៌អហិង្សា។

**ទី៧.** លើកកម្ពស់សុខុមាលភាពស្ត្រី តាមរយៈកម្មវិធីអាហារូបត្ថម្ភ សុខភាពបន្តពូជ និងជំងឺផ្សេងៗ

**ទី ៨.** បន្តពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន និងអ្នកពាក់ព័ន្ធ រួមទាំងនៅក្នុងតំបន់និងជាសកល។

**ទី៩.** បន្តអភិវឌ្ឍសមត្ថភាពស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងចូលរួមអនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ឱ្យស្របតាមការវិវត្តន៍របស់សង្គម។

# វេទិកា និងពិធីប្រគល់ពានរង្វាន់សហគ្រិនស្ត្រីអាស៊ាន ព្រឹត្តការណ៍អម កិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី២ ក្រោមប្រធានបទ ការកសាងអនាគតប្រកបដោយចីរភាព បរិយាប័ន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រី ក្នុងអាស៊ាន

**ភ្នំពេញ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០២២**

**តាមប្រព័ន្ធអនឡាញ និងនៅសណ្ឋាគារសូហ្វីតែល**





នៅឆ្នាំ២០២២នេះ ក្នុងឋានៈព្រះរាជាណាចក្រកម្ពុជាជាប្រធានអាស៊ាន ក្រសួងកិច្ចការនារី បានរៀបចំ**កិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២** ក្រោមប្រធានបទ «*ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីក្នុងអាស៊ាន*»។ នៅក្នុងព្រឹត្តិការណ៍អមកិច្ចប្រជុំកំពូលនេះ ក្រសួងកិច្ចការនារី ក្នុងកិច្ចសហការជាមួយបណ្តាញសហគ្រិនស្ត្រីកម្ពុជា (CamWEN) និងក្រុមប្រឹក្សាសហគ្រិនវ័យក្មេងអាស៊ាន (AYEC) បានរៀបចំ**វេទិកា និងពិធីប្រគល់ពានរង្វាន់សហគ្រិនអាស៊ាន** ដែលជាធាតុចូលដ៏សំខាន់ និងស៊ីចង្វាក់ជាមួយនឹងលទ្ធផលនៃកិច្ចប្រជុំកំពូលស្ត្រីអាស៊ាននាពេលអនាគតផងដែរ។

នៅក្នុងវេទិកាសហគ្រិនអាស៊ាន ដោយមានការចូលរួមជាវាគ្មិនពីសំណាក់ដៃគូពាក់ព័ន្ធ រួមមានតំណាង UNES-CAP, Oxfam, ERIA, អគ្គលេខាធិការដ្ឋានអាស៊ាន និងក្រសួងកិច្ចការនារី អង្គពិធីបានពិភាក្សាអំពីបញ្ហាប្រឈមនិងកាលានុវត្តភាពសំខាន់ៗសម្រាប់ការអភិវឌ្ឍសហគ្រិន




ភាពរបស់ស្ត្រីនៅអាស៊ាន និងជំរុញការផ្លាស់ប្តូរឆ្ពោះទៅរកការស្តារឡើងវិញនូវកំណើននិងភាពធន់រឹងមាំខ្លាំងក្លា នៃសហគ្រាសធុនមីក្រូតូច និងមធ្យម ដែលដឹកនាំដោយស្ត្រី។

នៅក្នុងនោះផងដែរ តាមរយៈកិច្ចពិភាក្សាក្នុងចំណោមសហគ្រិនស្ត្រីមកពីបណ្តាប្រទេសអាស៊ាន វេទិកាក៏បានក្លាយជាព្រឹត្តិការណ៍មួយក្នុងការជំរុញ និងលើកទឹកចិត្តដល់ស្ត្រីជាសហគ្រិន ក្នុងការដំណើរការអាជីវកម្ម ស្របតាមក្របខណ្ឌប្រតិបត្តិការស្តង់ដា នវានុវត្តន៍ និងប្រកបដោយច្នៃប្រឌិត។

ភ្ជាប់ជាមួយនឹងវេទិកានេះ កម្មវិធីក៏បានរៀបចំពិធីប្រគល់ពានរង្វាន់ពិសេសសម្រាប់សហគ្រិនស្ត្រីអាស៊ានឆ្នាំ២០២២ ដល់ស្ត្រីសហគ្រិនចំនួន៣៨រូប ដែលមកពីបណ្តាប្រទេសអាស៊ាន ដើម្បីបញ្ជាក់រំលេចអំពីការទទួលស្គាល់ ផ្តល់តម្លៃ និងអបអរសាទរដល់កិច្ចខិតខំប្រឹងប្រែងរបស់ស្ត្រីជាសហគ្រិននៅក្នុងតំបន់អាស៊ាន ក្នុងការចូលរួមក្នុងកំណើនសេដ្ឋកិច្ច ក្នុងប្រទេសរបស់ខ្លួន និងក្នុងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់។

លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានលើកឡើងថា ពានរង្វាន់ពិសេសសហគ្រិនស្ត្រីអាស៊ាននេះរៀបចំឡើងស្របតាមប្រធានបទ នៃកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ ដែលបានផ្តោតលើការលើកកម្ពស់សហគ្រិនភាពស្ត្រីអាស៊ាន ហើយនេះជាកំណត់ត្រាប្រវត្តិសាស្ត្រមួយរបស់អាស៊ាន។

សូមបញ្ជាក់ថា តាមរយៈកិច្ចសហការនិងគាំទ្រ ពីបណ្តាញសហគ្រិនស្ត្រីកម្ពុជាបណ្តាញសហគ្រិនស្ត្រីអាស៊ាន និងក្រុមប្រឹក្សាសហគ្រិនវ័យក្មេងអាស៊ាន នៅតាមបណ្តាប្រទេសនីមួយៗក្នុងអាស៊ាន កម្មវិធីនេះបានរៀបចំនិងជ្រើសរើសសហគ្រិនស្ត្រីដែលលេចធ្លោ ដើម្បីចូលរួមបានពានរង្វាន់នេះ ។

ព្រឹត្តិការណ៍នេះ ឧបត្ថម្ភគាំទ្រដោយស្ថានទូតកាណាដាប្រចាំនៅកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវផ្នែកសេដ្ឋកិច្ចនៅអាស៊ាន និងអាស៊ីបូព៌ា (ERIA) និងមានការចូលរួមពីបណ្តាតំណាងកិច្ចប្រជុំរដ្ឋមន្ត្រីកិច្ចការនារីអាស៊ាន គណៈកម្មាធិការអាស៊ានស្តីពីស្ត្រីបណ្តាញសហគ្រិនស្ត្រីអាស៊ាន ក្លឹបសហគ្រិនស្ត្រីវ័យក្មេងអាស៊ាន តំណាងស្ថានទូត កាណាដា និងបណ្តាប្រទេសអាស៊ាន អគ្គលេខាធិការដ្ឋានអាស៊ាន តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធនៅកម្ពុជា វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ចំនួន ២០០រូប ចូលរួមដោយផ្ទាល់នៅភ្នំពេញ និងប្រមាណ ៥០រូប តាមប្រព័ន្ធវីដេអូអនឡាញ ៕




សកម្មភាពក្នុងកិច្ចពិភាក្សាវគ្គទី១ ស្តីពីការអភិវឌ្ឍសហគ្រិនភាពរបស់ស្ត្រី និងការស្តារពីវិបត្តិកូវីដ-១៩ ប្រកបដោយបរិយាប័ន្ន នៅក្នុងតំបន់អាស៊ាន នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ




សកម្មភាពក្នុងកិច្ចពិភាក្សាវគ្គទី២ ស្តីពីគោលការណ៍ នៃការពង្រឹងភាពអង់អាចដល់ស្ត្រី៖ សម្លេង និងការឆ្លុះបញ្ចាំងពីស្ត្រីជាសហគ្រិន នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ










សកម្មភាព នៅក្នុងពិធីប្រគល់ពានរង្វាន់សហគ្រិនស្ត្រីអាស៊ាន នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ

# យុទ្ធនាការ ១៦ថ្ងៃ បញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី

## សកម្មភាពថ្នាក់ដឹកនាំក្រសួងកិច្ចការនារី ចូលរួមយុទ្ធនាការ ១៦ថ្ងៃ

## ចាប់ពីថ្ងៃទី២៥ វិច្ឆិកាដល់ថ្ងៃទី១០ ធ្នូ ឆ្នាំ២០២២



























# « អំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ»
















































# ពិធីប្រគល់ពានរង្វាន់សហគ្រិនវ័យក្មេងអាស៊ានលើកទី៧ ក្រោមមូលបទ " រីកចម្រើនឡើងវិញកាន់តែខ្លាំងទាំងអស់គ្នា" "RISE STRONGER TOGETHER" ដល់សហគ្រិន ផ្តើមមកពីបណ្តាប្រទេសអាស៊ាន









លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** បានចូលរួមជាគណៈអធិបតី និងប្រគល់ពានរង្វាន់សហគ្រិនវ័យក្មេងអាស៊ានលើកទី៧ ក្រោមមូលបទ " **រីកចម្រើនឡើងវិញកាន់តែខ្លាំងទាំងអស់គ្នា** " " **RISE STRONGER TOGETHER** " ក្នុងគោលបំណងឱ្យសហគ្រិនវ័យក្មេងអាស៊ាន ចែករំលែកបទពិសោធ និងឧត្តមានុវត្តន៍ ដើម្បីជំនះលើផលរំខានដែលបណ្តាលមកពីកូវីដ-១៩ តាមរយៈការធ្វើឌីជីថលភាវូបនីយកម្ម កិច្ចសហការ និងការសម្របខ្លួនទៅនឹងបរិបទថ្មីនេះ ដោយរៀបចំឡើងក្រោមកិច្ចសហការ នៃសមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC) ជាប្រធានក្រុមប្រឹក្សាសហគ្រិនវ័យក្មេងអាស៊ានឆ្នាំ២០២២ ជាមួយអង្គការបណ្តាញសហគ្រិនភាពសកលកម្ពុជា (GEN) និងក្រោមភាពជាដៃគូជាមួយក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ាន-កម្ពុជា (ASEAN-BAC) កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។ ក្នុងឱកាសនោះលោកជំទាវកត្តិបណ្ឌិត បានផ្តល់កិត្តិយសប្រគល់ពានរង្វាន់ចំនួន ៣ប្រភេទជូនសហគ្រិនផ្តើម ដែលមកពីបណ្តាប្រទេសអាស៊ាន រួមមាន៖ ពានរង្វាន់ពិសេសអាស៊ាន សម្រាប់សហគ្រិន ស្ត្រី (ASEAN Special Awards for Women Entre preneurs) ពានរង្វាន់ឧត្តមភាពអភិបាលកិច្ចសាជីវកម្ម (Corporate Governance Excellence Award) និងពានរង្វាន់អាជីវកម្មបៃតង (Green Business Award)៕

# សន្និបាតបូកសរុបលទ្ធផលការងារគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ប្រចាំឆ្នាំ២០២១ និង២០២២ និងលើកទិសដៅបន្តឆ្នាំ២០២៣ នៅសណ្ឋាគារភ្នំពេញ













ក្រសួងកិច្ចការនារី បានប្រារព្ធពិធីសន្និបាតបូកសរុបលទ្ធផលការងារគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ប្រចាំឆ្នាំ២០២១ និង ២០២២ និងលើកទិសដៅបន្តឆ្នាំ២០២៣ កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៣ នៅសណ្ឋាគារភ្នំពេញ។

អង្គសន្និបាតបានប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។ សន្និបាតមានគោលបំណងពិនិត្យ និងពិភាក្សាលើសមិទ្ធិផលការងារលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ឆ្នាំ២០២១ និងឆ្នាំ២០២២ រួមទាំងបញ្ហាប្រឈម និងទិសដៅបន្តជាអាទិភាពរបស់គណៈកម្មាធិការជាតិលើកកម្ពស់ សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ គ.ជ.ជ.ស.ខ ពិនិត្យឡើងវិញ និងផ្តល់ធាតុចូលលើផែនការសកម្មភាពប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន គ.ជ.ជ.ស.ខ ឆ្នាំ២០២៣។

ទន្ទឹមនឹងអង្គសន្និបាត បានអនុម័តក្នុងគំនិតបច្ចេកទេសលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិស្តង់ដា (SOP) ក្នុងការឆ្លើយតបលើកកម្ពស់សីលធម៌សង្គមតាមប្រព័ន្ធអនឡាញ ។

លេខាធិការដ្ឋាន គ.ជ.ជ.ស.ខ នឹងបញ្ជូនឯកសារ (SOP) ដែលអង្គសន្និបាតបានអនុម័ត ជូនទៅថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងសម្រេចមុននឹងអនុម័តប្រើប្រាស់ជាផ្លូវការ ។

សមាសភាពចូលរួមមាន សមាជិក សមាជិកា អន្តរក្រសួងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ថ្នាក់ដឹកនាំ និងក្រុមការងារលេខាធិការដ្ឋានគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និង និស្សិតមកពីសាកលវិទ្យាល័យចំនួន ៤មាន៖ (សាកល-វិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យកម្ពុជា) សរុបចំនួន ៣០០នាក់៕

# សិក្ខាសាលាពិគ្រោះយោបល់ និងចែករំលែកបទពិសោធន៍ស្តីពី "ថវិកាយេនឌ័រ" ដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូអនឡាញ




**លោកជំទាវ ខេង សំវ៉ាដា រដ្ឋលេខាធិការប្រចាំការ នៃក្រសួងកិច្ចការនារី រូបខាងឆ្វេង**



លោកជំទាវ **ខេង សំវ៉ាដា** រដ្ឋលេខាប្រចាំការ នៃក្រសួងកិច្ចការនារី បានអញ្ជើញធ្វើវាគ្មិនក្នុងបទអន្តរាគមន៍ នៃសិក្ខាសាលាពិគ្រោះយោបល់ និងចែករំលែកបទពិសោធន៍ស្តីពី **«ថវិកាយេនឌ័រ»**ដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូអនឡាញ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ នៅសណ្ឋាគារហ្កាឌិនស៊ីធី ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ។ សិក្ខាសាលានេះដឹកនាំដោយ ឯកឧត្តម **យ៉េត វណ្ណែល** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ) និងជាអគ្គលេខាធិការរង នៃ អ.គ.ហ. ដែលបានអញ្ជើញចូលរួមពីសំណាក់ លោកជំទាវ ឯកឧត្តម លោកស្រី លោក ជាក្រុមការងារវាយតម្លៃថវិកាយេនឌ័រក្នុងបរិបទកម្ពុជា សមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រុមការងារបច្ចេកទេសយេនឌ័រប្រចាំក្រសួង-ស្ថាប័ន តំណាងអង្គភាពហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័ន ក្រុមការងារបញ្ជ្រាបយេនឌ័ររបស់រដ្ឋបាលទាំង ២៥រាជធានី-ខេត្ត និងអង្គភាពជំនាញជុំវិញរដ្ឋបាលទាំង ២៥រាជធានី-ខេត្ត ព្រមទាំងក្រុមការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអង្គភាពក្រោមឱវាទ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន និងមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ(សហវ.) ទាំង ២៥រាជធានី-ខេត្ត សរុបចំនួន ១២០០នាក់ ។ សិក្ខាសាលាមានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីថវិកាយេនឌ័រ និងបង្កើនការចូលរួមក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សូមបញ្ជាក់ថា វាគ្មិនដែលចូលរួមក្នុងសិក្ខាសាលានេះ មានតំណាងមកពីក្រសួងកិច្ចការនារី តំណាងអគ្គនាយកដ្ឋានថវិកា នៃកសហវ. តំណាងក្រុមការងារបញ្ជ្រាបយេនឌ័ររបស់កសហវ. តំណាងក្រសួងអប់រំ យុវជន និងកីឡា តំណាងមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ត្រី នៃ អ.គ.ហ.។

# កិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីខមមីតលើកទី៥ ក្រោមប្រធានបទ «ពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគីឱ្យបានរឹងមាំ និងប្រកបដោយនិរន្តរភាព ដើម្បីបញ្ចប់អំពើជួញដូរមនុស្ស»







កាលពីថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០២២ លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី បានដឹកនាំកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីខមមីតលើកទី៥ ក្រោមប្រធានបទ **«ពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគីឱ្យបានរឹងមាំ និងប្រកបដោយនិរន្តរភាព ដើម្បីបញ្ចប់អំពើជួញដូរមនុស្ស»** រៀបចំដោយប្រទេសថៃ ដែលមានតំណាងប្រទេសចូលរួមចំនួន៦៖ កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ក្នុងនោះគណៈប្រតិភូរបស់កម្ពុជារួមមាន តំណាងមកពីក្រសួងកិច្ចការនារី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គការសម្ព័ន្ធចាប់ដៃ ក្នុងគោលបំណងពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការ ក៏ដូចជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីកសាង និងដាក់ឱ្យប្រើប្រាស់នូវការផ្តួចផ្តើម ការឆ្លើយតបរួមថ្មីមួយក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងប្រទេសមហាអនុតំបន់មេគង្គ៕

# ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "បន្ទប់បំបៅដោះកូន" នៅក្រសួងកិច្ចការនារី



កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "**បន្ទប់បំបៅដោះកូន**" នៅទីស្តីការក្រសួងកិច្ចការនារី ដោយសហការជាមួយអង្គការ ហេឡែនខេលល័រ និងគម្រោង MUSEFO នៃអង្គការ GIZ ក្នុងគោលបំណងដើម្បីជួយសម្រួលបន្ទុកដល់មន្ត្រីរាជការ និងបុគ្គលិកជាស្ត្រីដែលមានកូនតូច មានកន្លែងសមរម្យ ក្នុងការបន្តបំបៅដោះកូនប្រកបដោយអារម្មណ៍ស្រស់ស្រាយកក់ក្តៅនៅពេលដែលពួកគាត់ត្រឡប់មកបំពេញការងារវិញ ក្រោយពីការសម្រាកមាតុភាព។ ការបំបៅដោះកូនដោយទឹកដោះម្តាយពិតជាបានរួមចំណែកកាត់បន្ថយអត្រាមរណៈភាពរបស់មាតា ទារក និងកុមារ ព្រមទាំងជួយឱ្យកុមារមានសុខភាពល្អ មានប្រាជ្ញាឆ្លាតវាងវៃ ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភស្ត្រី និងកុមារ ស្របតាមការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការបង្កើនអត្រាការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ សម្រាប់ទារកអាយុពីសូន្យ ដល់ ៦ខែឱ្យបានដល់៨៥% នៅឆ្នាំ២០៣០។ ជាមួយគ្នានេះដែរ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី បានអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ រួមទាំងវិស័យឯកជន និងអង្គការសង្គមស៊ីវិល បើអាចធ្វើទៅបាន គួរបង្កើតបន្ទប់មួយដោយឡែកនៅក្នុងកន្លែងបំពេញការងាររបស់ខ្លួន ហើយត្រូវបំពាក់សម្ភារៈបរិក្ខារផ្សេងៗសម្រាប់មន្ត្រី និងបុគ្គលិករបស់ខ្លួនដែលជាស្ត្រីដែលមានកូនតូចអង្គុយបំបៅទារកដោយទឹកដោះរហូតដល់៦ខែ ឬរហូតដល់២ឆ្នាំ។ កម្មវិធីនេះមានអ្នកចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីក្រសួងកិច្ចការនារី ក្រសួងស្ថាប័នចំនួន២៧ និងអង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិលសរុបចំនួន ២០៧នាក់ (ស្ត្រី ១៨០នាក់)៕



**សកម្មភាពលោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "បន្ទប់បំបៅដោះកូន"**



**បន្ទប់បំបៅដោះកូន នៅក្រសួងកិច្ចការនារី**



**ថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ ចុះទស្សនកិច្ចស្វែងយល់ពីដំណើរការបង្កើតថ្នាក់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូន នៅក្រសួងកិច្ចការនារី**

**មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី**
**Women's Entrepreneurship Development Center**



## ការអភិវឌ្ឍសហគ្រិនភាពស្ត្រី

(គំនិតផ្តួចផ្តើម សម្រាប់សមភាពយេនឌ័រនិងអភិវឌ្ឍន៍សេដ្ឋកិច្ច)

Women's Entrepreneurship Development

(An Initiative for Gender Equality and Economic Development)

អនុវត្តតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់ រាជរដ្ឋាភិបាលកម្ពុជា និងក្នុងគោលដៅដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ជាពិសេសក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ក្រសួងកិច្ចការនារី បាននឹងកំពុងរៀបចំបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី ដោយផ្តោតលើសមាសភាគ ចំនួន៤ គឺ៖

១.កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍសហគ្រិន ភាពស្ត្រី
២.កម្មវិធីគាំទ្រដល់ការចាប់ផ្តើម និងអភិវឌ្ឍអាជីវកម្ម
៣.កម្មវិធីសិក្សាស្រាវជ្រាវ និង
៤.ការគាំទ្របណ្តាញនិងទីផ្សារសម្រាប់សហគ្រិន និងអាជីករជាស្ត្រី ។

### ក្រុមគោលដៅ និងទទួលផលពីកម្មវិធី៖

- សហគ្រិនស្ត្រីវ័យក្មេង និងស្ត្រីវ័យក្មេង
- អាជីវករស្ត្រី (កម្រិតមីក្រូ និងមិនផ្លូវការ)
- សហគ្រិនស្ត្រី (SMEs)

តាមរយៈការទទួលថវិកាពីរាជរដ្ឋាភិបាល ក្រសួងកិច្ចការនារីកំពុងចាប់ផ្តើមជួសជុល និងកែលំអឡើងវិញនូវអាគារដែលមានទីតាំងនៅជាប់វិទ្យាល័យ ហ៊ុន សែន ប៊ុន រ៉ានី វត្តភ្នំ ដើម្បីប្រើប្រាស់សម្រាប់ដំណើរការមជ្ឈមណ្ឌល និងកម្មវិធីនានាពាក់ព័ន្ធនឹងអភិវឌ្ឍន៍សហគ្រិនភាព និងអាជីវកម្មស្ត្រី ។

បន្ទាប់ពីទទួលបានពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្រសួងកិច្ចការនារី កំពុងពិភាក្សា និងស្វែងរកការគាំទ្របច្ចេកទេស និងប្រតិបត្តិកម្មវិធីក្នុងភាពជាដៃគូជាមួយនឹង UN-ECAP, ADB, GIZ, SHE Investment, Pact Cambodia និង ស្ថានទូតកាណាដាជាដើម។

# កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរួម (JCC) លើកទី៦ដើម្បីបញ្ចប់គម្រោង បញ្ជ្រាបយេនឌ័រ សម្រាប់បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE)













## សកម្មភាពក្នុងកិច្ចប្រជុំ



នៅសណ្ឋាគារតារាអ៊ែផត កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០២២ ក្រសួងកិច្ចការនារីបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរួម (JCC) លើកទី៦ ដើម្បីបញ្ចប់គម្រោងបញ្ជ្រាបយេនឌ័រ សម្រាប់បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE) ក្រោមអធិបតីភាពលោកជំទាវ **ចន្ទ សូរីយ៍** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។



កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណង ដើម្បីចែករំលែកបទពិសោធន៍ មេរៀនដែលទទួលបានតាមរយៈគម្រោង (PGM-WEE) និងការផ្តល់អនុសាសន៍ និងដើម្បីពិភាក្សាអនុម័តលើរបាយការណ៍បញ្ចប់គម្រោង និងទិសដៅបន្ត។

# វគ្គបណ្ដុះបណ្ដាលស្ដីពី ការលើកកម្ពស់ភាពជាអ្នកដឹកនាំជាស្ត្រី ៖ សិល្បៈ នៃការប្រាស្រ័យទាក់ទងប្រកបដោយឥទ្ធិពល





**លោកជំទាវ គឹម ស៊ីផាត់ រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី មានប្រសាសន៍ក្នុងអង្គពិធី**

កាលពីថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០២២ ក្រសួងកិច្ចការនារី សហការជាមួយក្រសួងមុខងារសាធារណៈ បានរៀបចំវគ្គបណ្ដុះបណ្ដាល ស្ដីពីការលើកកម្ពស់ភាពជាអ្នកដឹកនាំជា ស្ត្រី៖ សិល្បៈ នៃការប្រាស្រ័យទាក់ទងប្រកបដោយឥទ្ធិពល ។ វគ្គបណ្ដុះបណ្ដាលបានរៀបចំឡើងរយៈពេល ២ថ្ងៃ ដែលមានសិក្ខាកាមជាស្ត្រីដែលមានមុខតំណែងជាអគ្គនាយករង អគ្គាធិការរង នាយករង និងប្រធាននាយកដ្ឋាន នៃក្រសួង-ស្ថាប័ន និងក្រុមការងារសរុបចំនួន ៧៥រូប (ស្ត្រី៧០រូប)។

វគ្គបណ្ដុះបណ្ដាលនេះ មានគោលបំណង ដើម្បីអភិវឌ្ឍន៍សមត្ថភាពស្ត្រី ក្នុងវិស័យមុខងារសាធារណៈ អំពីភាពជាអ្នកដឹកនាំ និងសិល្បៈ នៃការប្រាស្រ័យទាក់ទង នៅក្នុងការអនុវត្តការងារប្រកបដោយឥទ្ធិពល៕



# ទស្សនៈយល់ដឹង ក្រោមមូលបទ « ស្ត្រីរួមគ្នារក្សាសុខសន្តិភាព



លោកស្រី **យូ សុភា** អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប ដើម្បីចូលរួមអបអរទិវាអន្តរជាតិនារី ៨មីនា ២០២៣ ដែលលើកឡើងថា «**ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍន៍ក្នុងយុគសម័យឌីជីថល**» ខ្ញុំយល់ឃើញថា៖ ការថែរក្សានូវសុខសន្តិភាព និងស្ថេរភាពនយោបាយ គឺជាកត្តាចាំបាច់ និងជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កិច្ចអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ដែលធានាបាននូវសុខុមាលភាពការរស់នៅរបស់ប្រជាជនប្រកបដោយភាពសុខដុមរមនា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលមានពាក្យស្លោក «ដឹងគុណសន្តិភាព អរគុណនយោបាយឈ្នះៗ ដឹងគុណស្ថាបនិកមគ្គុទេសឯក និងប្រតិបត្តិករនយោបាយឈ្នះៗ ដែលនាំមកនូវសន្តិភាព និងឯកភាពជាតិពេញលេញ។ ***មានសន្តិភាព គឺមានអ្វីៗទាំងអស់!*** ៕



លោក **ឈុំ រី** នាយកវិទ្យាល័យបាយ័ន ខេត្តសៀមរាប សម្រាប់ខ្ញុំ ជាដំបូងសូមអរគុណសន្តិភាព មានសន្តិភាព គឺមានអ្វីៗទាំងអស់ ក្នុងបរិបទនេះ គឺជាបរិបទថ្មី ក្រោយពីជួបនូវវិបត្តិកូវីដ-១៩ យើងទាំងអស់គ្នារស់នៅតាមបែបគន្លងថ្មី មិនថាបុរស ឬស្ត្រីទេ បានផ្លាស់ប្តូរឥរិយាបថក្នុងការទំនាក់ទំនងអាជីវកម្ម របៀបរបបទំនាក់ទំនងក្នុងការធ្វើការងារតាមរយៈប្រព័ន្ធបច្ចេកវិទ្យាថ្មី ក្នុងយុគសម័យឌីជីថល ដែលយើងគ្រប់គ្នាត្រូវការចាំបាច់ក្នុងការចាប់យក ដើម្បីឱ្យស្របតាមបរិវត្តកម្មឌីជីថល ដែលត្រូវធ្វើបដិវត្តន៍កម្មឧស្សាហកម្មទី៤ឆ្នាំ២០២១ ដល់ ២០៣៥។ ដោយសារមានសុខសន្តិភាព ជាពិសេសស្ត្រីបានចូលរួមក្នុងការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពទាំងការអប់រំចំណេះដឹង និងជំនាញ ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈការច្នៃប្រឌិត និងគណិតវិទ្យា ជាការរួមចំណែកដ៏សំខាន់ដែលធ្វើឱ្យជីវភាពរស់នៅរបស់ស្ត្រី និងគ្រួសារមានភាពប្រសើរឡើង ហើយស្ត្រីភាគច្រើនជាក្បាលម៉ាស៊ីនក្នុងការអភិវឌ្ឍន៍គ្រួសារ និងចូលរួមអភិវឌ្ឍន៍សង្គមជាតិ។ ដូចនេះ **សម្តេចតេជោ ជាឆ័ត្រសន្តិភាពសម្រាប់កម្ពុជា** ក្នុងការរក្សាបាននូវសុខសន្តិភាព មានការអភិវឌ្ឍន៍លើគ្រប់វិស័យ ៕



លោកស្រី **ឌុច ម៉ាលីន** មេឃុំយាង ស្រុកពួក ខេត្តសៀមរាប តាមទស្សនៈខ្ញុំយល់ឃើញថា៖. បើគ្មានសន្តិភាពទេ គឺយើងគ្មានអ្វីៗទាំងអស់ កន្លងមកប្រទេសកម្ពុជាយើងបានឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃ វាលពិឃាដ នាសម័យប៉ុលពតបានសម្លាប់ប្រជាពលរដ្ឋជាច្រើនរាប់លាននាក់ និងបានបន្សល់ទុកនូវគ្រាប់មិនទាន់ផ្ទុះ ដែលធ្វើឱ្យប្រជាពលរដ្ឋកម្ពុជា និងជនបរទេសមានការភ័យខ្លាចគ្រប់ៗគ្នា ក្នុងការមកលេងកម្សាន្តនៅប្រទេសយើង។ ប៉ុន្តែបច្ចុប្បន្ននេះតាមគោលនយោបាយលក្ខណៈសម្បត្តិ ៧យ៉ាងរបស់ភូមិឃុំមានសុវត្ថិភាព ប្រទេសកម្ពុជាយើងបានប្រែក្លាយជាប្រទេសមួយដែលមានសុខសន្តិភាព សុវត្ថិភាព និងជាតំបន់ទេសចរណ៍លំដាប់សកល ប្រកបដោយប្រជាប្រិយភាព និងស្នាមញញឹមរបស់ពលរដ្ឋគ្រប់រូប ។ នាងខ្ញុំសូមថ្លែងអំណរគុណ និងដឹងគុណដល់ប្រមុខរាជរដ្ឋាភិបាល ដែលដឹកនាំប្រទេសឱ្យទទួលបានសុខសន្តិភាព និងសុវត្ថិភាព ជានិរន្តរ៍។ ***សន្តិភាពកើតឡើងពីស្នាមញញឹម!*** ៕

# ដើម្បីការអភិវឌ្ឍ ក្នុងយុគសម័យឌីជីថល »



លោកស្រី **កុយ មុច្ឆា** ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តស្វាយរៀងបានលើកឡើងថា «**ខ្ញុំសូមអរគុណសន្តិភាព និងសូមអរគុណដល់ការដឹកនាំរបស់សម្តេចតេជោដែលតែងតែនាំមកនូវសុខសន្តិភាព**»។ ខ្ញុំយល់ឃើញថា បច្ចុប្បន្ននេះ ស្ត្រីនិងបុរស មានសិទ្ធិ និងមានឱកាសដូចគ្នាក្នុងការចូលរួមសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច។ ជាក់ស្តែង យើងមើលឃើញថាអាជីវករភាគច្រើនគឺជាស្ត្រី ដែលកាលពីមុនស្ត្រីភាគច្រើនគឺនៅតែផ្ទះ មើលថែទាំផ្ទះ និងសមាជិកគ្រួសារ»។ ហេតុនេះប្រសិនបើពួកគាត់មានចំណេះដឹងផ្នែកឌីជីថលបន្ថែមទៀត គាត់នឹងមានឱកាសកាន់តែច្រើនដើម្បីចាប់យកទីផ្សារ និងបង្កើនប្រាក់ចំណូលកាន់តែច្រើន៕



លោក **ទេព ថា** អាជីវករលក់គ្រឿងសំណង់នៅក្រុងស្វាយរៀងបានលើកឡើងថា «**និយាយទាក់ទងនឹងសុខសន្តិភាពរបស់ប្រទេសជាតិ និងការអភិវឌ្ឍន៍របស់ប្រទេសជាតិខ្ញុំក៏សូមអរគុណដល់សម្តេចនាយករដ្ឋមន្ត្រីផងដែរ ដែលតែងតែនាំមកនូវសុខសន្តិភាពជូនប្រជាពលរដ្ឋ និងប្រទេសជាតិ**»។ ក្រោមម្លប់នៃសន្តិភាព យើងឃើញថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិសេរីភាព ពេញលេញក្នុងការទទួលបានការអប់រំ សិទ្ធិរស់នៅក្នុងការដើរហើរ និងប្រកបរបររកស៊ីនានា ព្រមទាំងទទួលបានផលពីការអភិវឌ្ឍន៍លើគ្រប់វិស័យ។ បច្ចុប្បន្នយើងឃើញថាមានការរីកចំរើនច្រើននៅក្នុងប្រទេសយើង ហើយប្រសិនបើគ្មានសន្តិភាព ក៏យើងគ្មានថ្ងៃនេះដែរ។ ដូចនេះយើងត្រូវបន្តរួមគ្នារក្សាសុខសន្តិភាព ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិយើងឱ្យកាន់តែរីកចម្រើន ជាពិសេសក្នុងយុគសម័យឌីជីថលនេះ៕



លោកស្រីឧត្តមសេនីយ៍ត្រី **កែវ សាត់** ស្នងការរងទទួលបន្ទុកផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ខេត្តស្វាយរៀង បានលើកឡើងថា «**បច្ចុប្បន្នស្ត្រីក៏ជាកម្លាំងជួរមុខក្នុងការចូលរួមការពារ សុវត្ថិភាព និងថែរក្សាសុខសន្តិភាព។ ការរក្សាបាននូវសុខសន្តិភាព ជាលក្ខខណ្ឌចាំបាច់ដែលមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍន៍ប្រទេសមួយ ពីព្រោះបើគ្មានសុខសន្តិភាព ក៏អ្នកវិនិយោគទាំងក្នុងស្រុក និងបរទេសក៏មិនហ៊ានវិនិយោគក្នុង ប្រទេសយើងដែរ**»។ ក្នុងយុគសម័យឌីជីថលនេះទៀត ការប្រើប្រាស់ នូវបច្ចេកវិទ្យាបែបបទំនើប ក៏ធ្វើឱ្យស្ត្រីមានឱកាសកាន់តែច្រើនក្នុងការចូលរួមការងារបានយ៉ាងពេញលេញ ក្នុងការស្រាវជ្រាវ តាមដានករណីដឹកនាំការងារ ឬចុះបញ្ជាផ្ទាល់សម្រាប់ការបង្ក្រាបបទល្មើសផ្សេងៗ ហើយថែមទាំងអាចទំនាក់ទំនងគ្នា ដឹងព័ត៌មានពីគ្នាទាំង ២៥រាជធានី-ខេត្ត តាមរយៈកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ និងស្មាតហ្វូនជាដើម។ បើប្រៀបធៀបពីមុនវិញ ពេលប្តីចេញទៅបម្រើការងារកងទ័ព ស្ត្រីគឺជាកម្លាំងដែលនៅពីខាងក្រោយ ក្នុងការថែទាំសមាជិក នៅក្នុងគ្រួសារ បើចង់ដឹងសុខទុក្ខប្តីម្តងៗ ត្រូវរង់ចាំពេលវេលាក្នុងការផ្ញើសំបុត្រទាក់ទងគ្នា តែសម័យបច្ចេកវិទ្យាទំនើប នេះវិញ មិនថាប្តីប្រពន្ធ កូននៅទីណាទេ គឺយើងអាចទំនាក់ទំនងគ្នាបានភ្លាមៗចង់ឃើញមុខគ្នាក៏បានដែរ៕

# ស្ត្រីមេឃុំ/ចៅសង្កាត់ដែលជាប់ឆ្នោត ៥ អាណត្តិជាប់ៗគ្នាពីឆ្នាំ ២០០២-២០២៧

ចាប់តាំងពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី១ (២០០២-២០០៧) មានស្ត្រីជាមេឃុំ ចំនួន ៤២នាក់។ អាណត្តិទី២ (២០០៧-២០១២) មានស្ត្រីជាមេឃុំចំនួន ៦៧នាក់ ។ អាណត្តិទី៣ (២០១២-២០១៧) មានស្ត្រីជាមេឃុំចំនួន ១១៥នាក់។ អាណត្តិទី៤ (២០១៧-២០២២) មានស្ត្រីជាមេឃុំចំនួន ១៣០នាក់។ អាណត្តិទី៥ (២០២២-២០២៧) មានស្ត្រីជាមេឃុំចំនួន ១៧៣នាក់។ ស្ត្រីដែលជាប់ជាមេឃុំ-ចៅសង្កាត់បាន៥អាណត្តិជាប់ៗគ្នាមានចំនួន ០៨នាក់។

## រាជធានីភ្នំពេញ

**លោកស្រី តៅ មន្ថា**



ចៅសង្កាត់បឹងព្រលិត
ខណ្ឌ ៧មករា

**លោកស្រី ប្រាក់ ម៉ាលី**



ចៅសង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន

**លោកស្រី ប៉ែន អ៊ិន**



ចៅសង្កាត់ផ្សារកណ្តាលទី២
ខណ្ឌ ដូនពេញ

## ខេត្តសៀមរាប

**លោកស្រី ឌុច ម៉ាលីន**



មេឃុំយាង ស្រុកពួក

**លោកស្រី ពុទ្ធ ចិន្តា**



មេឃុំជីក្រែង ស្រុកជីក្រែង

## ខេត្តស្វាយរៀង

**លោកស្រី ទេព សោមុន្នី**



មេឃុំគោព្រីង ស្រុកស្វាយជ្រំ

## ខេត្តព្រះវិហារ

**លោកស្រី សោម សុខុម**



មេឃុំចំរើន ស្រុកសង្គមថ្មី

## ខេត្តកំពង់ចាម

**លោកស្រី ហៀង សុផល**



មេឃុំ មេព្រីង ស្រុកបាធាយ

# ពីក្មេងស្រីចូលចិត្តលេងឡានបញ្ហា ទៅជានិស្សិត អាហារូបករណ៍ជំនាញវិស្វកម្មមេកានិក នៅសហរដ្ឋអាមេរិក





យុវតី **ស៊ីន លេហ្វា** មានវ័យ ១៧ឆ្នាំ កើតក្នុងឆ្នាំ ២០០៥ នៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង បានជាប់ជានិស្សិតអាហារូបករណ៍ជំនាញវិស្វកម្មមេកានិក ដែលផ្តល់ដោយសាកលវិទ្យាល័យ Union College នៅក្រុងញូវយ៉ក សហរដ្ឋ-អាមេរិក ដោយសារចូលចិត្តលេងឡានបញ្ជាតាំងពីតូច។

**លេហ្វា**បានរៀបរាប់ថា៖ *«ខ្ញុំចូលចិត្តលេងឡានបញ្ជាតាំងពីអាយុ៨-៩ឆ្នាំ និងចូលចិត្តដើររើសរបស់ចាស់ៗមកច្នៃធ្វើជារបស់លេង ដូចជា កែច្នៃទៅជាទូកជាដើម»*។

**លេហ្វា**បានរៀបរាប់បន្តថា៖ *«ខ្ញុំស្រឡាញ់ជំនាញវិស្វកម្មមេកានិច ដោយសារខ្ញុំចូលចិត្តច្នៃរបស់របរ និងលេងឡានបញ្ជាតាំងពីនៅវ័យក្មេង វាសមនឹងអ្វីដែលខ្ញុំចូលចិត្ត ដើម្បីបន្តធ្វើវានៅពេលអនាគត»* ។

**លេហ្វា**បន្ថែមថា *«កាលមុនខ្ញុំមានភាពស្ទាក់ស្ទើរ ដោយសារម្តាយរបស់ខ្ញុំប្រាប់ថា ជំនាញវិស្វកម្មមិនសូវមានស្ត្រីធ្វើទេ ប៉ុន្តែពេលខ្ញុំមានកុំព្យូទ័រប្រើ ក៏ចាប់ផ្តើមស្រាវជ្រាវទៅទើបដឹងថា ការងារវិស្វកម្មមិនសំខាន់លើភេទទេ»*។

នៅក្នុងឆ្នាំ២០១៦ តាមរយៈអាហារូបករណ៍របស់សាលាភាពជាអ្នកដឹកនាំ Liger (Liger Academic Leadership)។ ពេលនោះ នាងទើបមានអាយុត្រឹម១១ ឆ្នាំ និងទើបបញ្ចប់ថ្នាក់បឋមសិក្សាតែប៉ុណ្ណោះ។

**លេហ្វា**បានលើកឡើងថា៖ *«តាមពិតទៅមានឱកាសមករៀននៅភ្នំពេញ គឺជារឿងដែលមិនបានព្រាងទុកខ្ញុំអត់ដឹងថា វាជាអាហារូបករណ៍អ្វីទេ ពេលបើកបវេសនកាលចូលរៀនថ្នាក់ទី៧ គ្រូប្រចាំថ្នាក់ទី៦របស់ខ្ញុំបានដាក់ពាក្យជំនួសខ្ញុំឱ្យប្រឡងយកអាហារូបករណ៍មិនបានសួរខ្ញុំមុនឡើយ ដោយប្រាប់ថាគេរើសយកសិស្សពីរនាក់ ក្នុងនោះមានស្រីម្នាក់ និងប្រុសម្នាក់ពីសាលាស្នាច់មានជ័យ ទើបខ្ញុំសាកល្បងចូលប្រឡងនឹងគេ»* ហើយសិស្ស ចូលរួមប្រកួតមានជាង៥០នាក់ ក្នុងខេត្តកោះកុង។ ក្រោយឆ្លងកាត់ការប្រឡងជម្រុះ មានសិស្សតែបីនាក់ប៉ុណ្ណោះដែលជាប់ ហើយត្រូវបន្តប្រឡងជម្រុះនៅវគ្គចុងក្រោយ។

ឆ្លងកាត់ការសិក្សារយៈពេល៦ឆ្នាំនៅសាលាភាពជាអ្នកដឹកនាំ Liger យុវតីរូបនេះបានក្រេបជញ្ជក់យកចំណេះដឹងអាចកសាងសមត្ថភាពជំនាញ និងស្វែងយល់ពីបំណិនជីវិតសំខាន់ជាច្រើន នាងមានឱកាសកសាងសមត្ថភាពរបស់ខ្លួនតាមរយៈការដឹកនាំគម្រោងជួយគាំទ្រដល់ក្មេងស្រី ដែលស្រឡាញ់ជំនាញវិស្វកម្ម មានឈ្មោះថា **«វិស្វកម្មសម្រាប់យុវតី»** ចាប់តាំងពីនាងរៀនថ្នាក់ទី១១ នៅឆ្នាំ២០២០ ផ្តោតសំខាន់លើសិស្សស្រីថ្នាក់ទី៧ និងទី៨ នៅអនុវិទ្យាល័យរទាំង ស្ថិតនៅក្នុងរាជធានីភ្នំពេញ។ យុវតី **លេហ្វា** បានបញ្ចប់ថ្នាក់វិទ្យាល័យដោយជោគជ័យក្នុងឆ្នាំ២០២២។

លោកស្រី **Caroline Bell** នាយិកាសាលាភាពជាអ្នកដឹកនាំ Liger បានបង្ហាញមោទនភាព និងទំនុកចិត្តខ្ពស់ចំពោះសិស្សស្រីរបស់ខ្លួនរូបនេះ ដែលនឹងត្រូវចាកចេញទៅបន្តការសិក្សាជំនាញវិស្វកម្មមេកានិចនៅពាក់កណ្តាលឆ្នាំ ២០២៣ នេះថា *«ក្នុងនាមជានាយិការបស់* ***លេហ្វា*** *ផ្ទាល់ខ្ញុំមើលឃើញថា នាងជាសិស្សឆ្នើមម្នាក់ក្នុងចំណោមសិស្សពូកែជាងគេក្នុងសាលា ទាំងទេពកោសល្យផ្នែកសិក្សា និងការប្រឹងប្រែងយ៉ាងខ្លាំង ជឿទុកចិត្តចំពោះអ្វីដែលខ្លួនកំពុងធ្វើ ដើម្បីសម្រេចគោលដៅ»*។

បើតាមសំដី**លេហ្វា**បានបញ្ជាក់ថា៖« *ពេលបញ្ចប់ការសិក្សាខ្ញុំនឹងមកកម្ពុជា ដើម្បីលើកស្ទួយវិស័យវិស្វកម្មនេះ សម្រេចតាមក្តីស្រមៃរបស់ខ្ញុំ គឺចង់ឃើញខ្មែរយើងដើរទៅរកបច្ចេកវិទ្យាទំនើប និងមានវិស័យវិស្វកម្មជឿនលឿន»* ហើយ *«ខ្ញុំចង់ចូលក្នុងវិស័យផលិតឡានអគ្គិសនី ខ្ញុំសង្ឃឹមថា ទៅថ្ងៃខាងមុខមានស្ត្រីជាច្រើនរៀនជំនាញនេះ ប្រទេសយើងនឹងមានការអភិវឌ្ឍលឿនដូចបណ្តាប្រទេសដទៃ »*៕

***ដកស្រង់ពីបណ្តាញសង្គមថ្មីៗ***

# ព្រឹត្តការណ៍ស៊ីហ្គេមលើកទី៣២ (32nd SEA Games) និង អាស៊ានប៉ារ៉ាហ្គេម (12th ASEAN Para Games)



**ម្ចាស់មេដាយមាស និងសំរឹទ្ធ កីឡាវ៉ូវីណាម ប៉ាល់ ឆវស្មី**

កម្ពុជាបានត្រៀមខ្លួនរួចរាល់ « Cambodia is Ready » ចាំទទួលស្វាគមន៍យ៉ាងកក់ក្តៅជូនដល់ប្រតិភូកីឡា និងការត្រៀមរៀបចំព្រឹត្តិការណ៍កីឡាដ៏ធំជាប្រវត្តិសាស្ត្រលើកដំបូងនៅកម្ពុជា ក្រោយការរង់ចាំអស់រយៈពេល៦៤ឆ្នាំនេះ។ ការធ្វើជាម្ចាស់ផ្ទះ នៃព្រឹត្តិការណ៍កីឡាស៊ីហ្គេម និងម៉ាប៉ាហ្គេម គឺជាមោទនភាព និងមុខមាត់សម្រាប់ប្រទេស និងប្រជាជនកម្ពុជាទាំងមូល។

ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសពិតជាមានមោទនភាព ដែលកម្ពុជាបានបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀត ក្នុងទស្សនាទានការទូតកីឡា និងកិត្យានុភាពជាតិ ក្នុងការនាំមកនូវទង់សហព័ន្ធកីឡា SEA Games លើកទី៣២ នៅកម្ពុជា។

ជ័យលាភីទាំង ៦៣មេដាយ (មេដាយមាសចំនួន៩ មេដាយប្រាក់ចំនួន១៣ និងមេដាយសំរឹទ្ធចំនួន៤១) ដែលដណ្តើមបាន និងកត់ត្រាបន្ថែមក្នុងប្រវត្តិសាស្ត្រកីឡា SEA Games ដែលកម្ពុជាបំបែក ឯតទគ្គកម្មមេដាយច្រើនជាង SEA Games មុនៗកន្លងមក និងជាសញ្ញាណល្អប្រពៃណាស់ សម្រាប់ស្វែងរកឧត្តមភាពមេដាយច្រើនថែមទៀតក្នុងការប្រកួត SEA Games ឆ្នាំ២០២៣ នៅកម្ពុជា។

គួរដឹងថា កីឡាស៊ីហ្គេមលើកទី៣២ នៅកម្ពុជា នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងកីឡាអាស៊ានប៉ាប៉ាហ្គេម លើកទី១២ នៅកម្ពុជាចាប់ផ្តើមការប្រកួតពីថ្ងៃទី០៣-០៩ ខែមិថុនា ឆ្នាំ២០២៣។ ប៉ុន្តែមុនឈានដល់ការប្រកួត គណៈកម្មការ អនុគណៈ



**ក្រុមកីឡាការិនីបាល់បោះជិះរទេះជនពិការកម្ពុជា បានក្លាយជាម្ចាស់ពានរង្វាន់ ICRC International Wheelchair Basketball Tournament លើកទី៣ បន្ទាប់ពីបានយកឈ្នះក្រុមកីឡាការិនីម្ចាស់ផ្ទះឥណ្ឌា**

កម្មការ នៃគណៈកម្មាធិការជាតិ CAMSOC និងភាគីពាក់ព័ន្ធនឹងត្រូវមានការងារជាច្រើន ត្រូវយកចិត្តទុកដាក់បន្ថែម ដូចជាការត្រៀមរៀបចំព្រះរាជពិធីសុំភ្លើងព្រះអគ្គីកីឡា នៅប្រាសាទអង្គរវត្តនាថ្ងៃទី២១ ខែមីនាខាងមុខ ដើម្បីដង្ហែរភ្លើងគប់ជុំវិញបណ្តាប្រទេសអាស៊ាន និងបឹងទន្លេសាប រហូតដល់ពេលវេលាប្រារព្ធពិធីបើកការប្រកួត កីឡាស៊ីហ្គេម លើកទី៣២ ជាផ្លូវការតែម្តង៕



**វីរកីឡាការិនីប៉េតង់ អ៊ុក ស្រីមុំ ម្ចាស់មេដាយមាស ពិភពលោក ឆ្នាំ២០២២**




**ស្រួង ភាវី ជើងឯកកីឡាប៊ីយ៉ាការ៉ុម លំដាប់ពិភពលោក**



**កីឡាការិនី សន និច ហាត់កីឡាគុនដាវ ៧ឆ្នាំ ក្តីស្រមៃធំបំផុតគឺនាំយកមេដាយជូនជាតិ នាស៊ីហ្គេម២០២៣**

# អបអរសាទរ វរកីឡាការិនី ខាន់ ចេសា ដណ្ដើមបានមេដាយមាសកីឡាជីជីតស៊ូជើងឯកពិភពលោក នៅអារ៉ាប់រួម




កីឡាការិនីជីជីតស៊ូកម្ពុជា **ខាន់ ចេសា** ដណ្ដើមបានមេដាយមាស នៃការប្រកួតកីឡាជីជីតស៊ូជើងឯកពិភពលោក Ju-Jitsu World Championship - Abu Dhabi 2022 ហើយ ក្រោយយកឈ្នះកីឡាការិនីអេស្ប៉ាញ Matthews Martin Naiomi ក្នុងវគ្គផ្ដាច់ព្រ័ត្រ នៅទីក្រុងអាប៊ូដាប៊ី ប្រទេសអារ៉ាប់រួម។

សម្រាប់ការប្រកួតលើវិញ្ញាសា Jiu Jitsu (Newaza) ទម្ងន់ក្រោម ៥២គីឡូក្រាម ធ្វើបានយ៉ាងល្អ ក្នុងនាមកីឡាការិនីឈរចាំនៅជុំទី២ ដោយកញ្ញាបានយកឈ្នះគូប្រកួតដោយផ្ដួលឱ្យបោះបង់ការប្រកួតចំនួន ៣ប្រកួតជាប់គ្នា ពោលគឺ **ចេសា** បានផ្ដួលកីឡាការិនីហ្វីលីពីន Baluyot Ashley Jeraine នៅជុំទី២ (១៦នាក់ចុងក្រោយ) ផ្ដួលកីឡាការិនីម្ចាស់ផ្ទះអារ៉ាប់រួម Shraim Maitha នៅជុំទី៣ (វគ្គ ៨នាក់ចុងក្រោយ) និងផ្ដួលកីឡាការិនីអ៊ីស្រាអ៊ែល Aronov Pnina នៅវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រ កាលពីថ្ងៃមិញ។

ឈានដល់វគ្គផ្ដាច់ព្រ័ត្រ កីឡាការិនីកូនកាត់ ៣សាសន៍ (ខ្មែរ-អាមេរិក-ម៉ិកស៊ិក) នៅតែរក្សាភាពខ្លាំងរបស់ខ្លួន ដោយ **ខាន់ ចេសា** បានប្រើស្នៀតពិសេសចាប់ឃ្លេកីឡាការិនីជើងខ្លាំងអេស្ប៉ាញ Matthews Martin Naiomi ជាប់ពេញរយៈពេល ៦នាទី ដែលនាំឱ្យគណៈកម្មការផ្ដល់ជ័យជម្នះដល់កីឡាការិនីវ័យ ២១ឆ្នាំរបស់កម្ពុជា ដើម្បីគ្រងមេដាយមាស នៃការប្រកួតជើងឯកពិភពលោក ឆ្នាំ២០២២ ជូនប្រទេសកម្ពុជា៕

*ដកស្រង់ចេញពីវេបសាយ*

# មានតែចំណេះវិជ្ជាទេ ដែលជាស្ពាននាំយើងចេញពីភាពក្រីក្របាន



លោកជំទាវឧកញ៉ា **ម៉ែន ចិន្តា** ជាអភិបាលក្រុមហ៊ុន ដេខេ ប្រធីធី ដែលជាអ្នកជំនួញវ័យក្មេង កើតចេញពីគ្រួសារក្រីក្រជាអ្នកលក់នំបញ្ចុកគីឡូ និងចិញ្ចឹមជ្រូក រស់នៅភូមិបាត់សេមាន់ ឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានបងប្អូន ៣នាក់ លោកជំទាវជាកូនច្បង ឪពុកជាប៉ូលីស និងអ្នកម្តាយជាស្ត្រីមេផ្ទះ។

លោកជំទាវឧកញ៉ា **ម៉ែន ចិន្តា** បានមានលើកឡើងថា ដោយជីវភាពក្រលំបាក ត្រូវរងនូវការមាក់ងាយពីមជ្ឈដ្ឋានជុំវិញគ្រប់បែបយ៉ាង។ ***«ខ្ញុំគិតថា ដើម្បីឱ្យគ្រួសារចាកចេញពីភាពក្រីក្រ ភាពមាក់ងាយ នឹងមានជីវភាពប្រសើរឡើងគឺមានតែចំណេះវិជ្ជាទេដែលជាស្ពាននាំយើងចាកចេញពីស្ថានភាពនេះបាន»*** ទោះមានភាពលំបាកក្នុងជីវភាពយ៉ាងណាក៏ដោយ ក៏នាងខ្ញុំមិនដែលបោះបង់ការសិក្សាឡើយ ក្រៅពីសិក្សានៅសាលារដ្ឋហើយ នាងខ្ញុំក៏សម្រេចចិត្តខំរៀនភាសាអង់គ្លេសក្រៅម៉ោងថែមទៀត ដោយសុំគ្រូនៅសាលារដ្ឋចេញមុនកន្លះម៉ោងជារៀងរាល់ថ្ងៃដើម្បីបានទៅរៀនភាសាអង់គ្លេស (នាងខ្ញុំមិនដែលបានរៀននៅក្នុងថ្នាក់ដូចគេឯងទេ នាងខ្ញុំត្រូវឈររៀននៅក្រៅថ្នាក់ ព្រោះថាមិនមានថវិកាសម្រាប់បង់ជូនគ្រូ) ហើយចប់ម៉ោងរៀននាងខ្ញុំត្រូវទៅជួយលក់នំបញ្ចុកម្តាយបន្ត។ លោកជំទាវឧកញ៉ាបានរៀបរាប់ថា ហេតុតែយើងក្រីក្រ យើងមិនសូវមានមិត្តភក្តិទេ តែដោយសារនាងខ្ញុំជាសិស្ស ពូកែមុខវិជ្ជាគណិតវិទ្យា ទើបរៀងរាល់ចុងខែ មានមិត្តភក្តិមកនិយាយជាមួយ ។

ទោះជាខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ដោយជីវភាពក្រីក្រហើយម្តាយធ្លាក់ខ្លួនឈឺ ខ្លួនជាកូនច្បងត្រូវរ៉ាប់រងគ្រួសារជំនួសម្តាយ លោកជំទាវឧកញ៉ា បានឈប់រៀនត្រឹមថ្នាក់ទី៩ រួចបានចូលធ្វើការជាអ្នកបកប្រែភាសាអង់គ្លេសឱ្យក្រុមហ៊ុនជនជាតិកូរ៉េនៅខេត្តព្រះសីហនុ។ លោកជំទាវបានរៀបរាប់ថា ទោះយ៉ាងនេះក្តីលោកជំទាវឧកញ៉ាមិនបញ្ចប់ការសិក្សាត្រឹមនេះទេ ក្រោយមកលោកជំទាវបានបន្តការសិក្សាបន្ថែមនៅក្នុងឆ្នាំ២០០១ ទទួលបានបរិញ្ញាបត្ររងផ្នែកច្បាប់នៅមហាវិទ្យាល័យបៀលប្រាយ ។

នៅឆ្នាំ២០០៣ បានរៀបការជាមួយជនជាតិកូរ៉េ និងបានកូនប្រុសម្នាក់ ។ ក្នុងឆ្នាំ២០១០ លោកជំទាវឧកញ៉ា និងកូនបានទៅរស់នៅប្រទេសកូរ៉េជាមួយម្តាយក្មេក ***«ពេលនោះខ្ញុំគិតស្មានថាបានសុខស្រួលលែងក្រីក្រទៀតហើយ»*** តែខុសស្រឡះ ទៅដល់ទីនោះដោយសារប្រពៃណី និងវប្បធម៌ខុសគ្នា ហើយស្វាមីក៏មិនឧបត្ថម្ភប្រាក់កាសឱ្យទៀត និងបានលែងលះគ្នានៅឆ្នាំ២០១២ ពេលខ្លះខ្ញុំក៏ចង់គិតខ្លីម្តងៗដែរ តែដោយសារកូនក៏ខំប្រឹងតស៊ូរស់បន្តទៀត។ លោកជំទាវឧកញ៉ាបានរៀបរាប់បន្ថែមថា អ្វីដែលខ្ញុំបានកំណត់ និងជំនះចិត្តកន្លងមកដែលថាមានតែចំណេះវិជ្ជាទេ ដែលអាចជួយយើងឱ្យចាកចេញពីភាពលំបាក និងភាពក្រីក្របាននោះ ទើបនាងខ្ញុំត្រូវខំរៀនភាសាកូរ៉េឱ្យចេះ ខ្ញុំរៀនបានរយៈពេល ៥ខែ នាងខ្ញុំអាចនិយាយភាសាកូរ៉េ ។

បន្ទាប់មកលោកជំទាវឧកញ៉ាបានទៅធ្វើការរោងចក្រមួយក្នុងប្រទេសកូរ៉េ ហើយក្នុង១ថ្ងៃត្រូវធ្វើការ ៧ម៉ោង





***រូបសកម្មភាពលោកជំទាវឧកញ៉ា ម៉ែន ចិន្តា ទទួលបានប័ណ្ណសរសើរក្នុងការជួយដល់ពលករខ្មែរ នៅប្រទេសកូរ៉េ***

សល់ពេលទំនេរពីការងារ ដើម្បីកុំឱ្យខ្លួនកើតទុក្ខច្រើន គឺត្រូវធ្វើខ្លួនឱ្យរវល់ ដោយឆ្លៀតពេលទៅធ្វើការងារសង្គមជាអ្នកស្ម័គ្រចិត្តកាកបាទក្រហម (ដោយមិនយកកម្រៃ) ជួយដល់ពលករខ្មែរដែលរងគ្រោះ ជាពិសេសស្ត្រី ដោយសារស្វាមីធ្វើបាប ព្រមទាំងជួយស្ត្រីជនជាតិកូរ៉េផងដែរ។ លោកជំទាវឧកញ៉ាបានបញ្ជាក់បន្ថែមថា ដោយឡែកចំពោះការបកប្រែភាសាពីកូរ៉េមកជាភាសាខ្មែរ គឺប៉ូលីសបានគិតប្រាក់កម្រៃឱ្យក្នុង១ម៉ោង ៥០ដុល្លារ ក្នុង១ថ្ងៃធ្វើការ ៦ម៉ោង សរុប ៣០០ដុល្លារ ***«ខ្ញុំមានក្តីរំភើបខ្លាំងណាស់នូវប្រាក់កម្រៃ ដែលខ្ញុំទទួលបានពីចំណេះដឹងរបស់ខ្ញុំពីការបកប្រែភាសា»***។

មូលហេតុដែលលោកជំទាវឧកញ៉ាចូលធ្វើការងារសង្គម ដោយសាររូបលោកជំទាវឧកញ៉ាផ្ទាល់ជួបទុក្ខលំបាក ហើយត្រូវការអ្នកជួយខ្លាំងណាស់ ***«ពេលខ្ញុំមានទុក្ខ និងមានបញ្ហា ពេលមានអ្នកជួយជីវិតខ្ញុំស្រស់បំព្រងឡើងវិញ»*** ដូចនេះហើយដែលជាកត្តាជម្រុញឱ្យខ្ញុំចូលរួមក្នុងការងារសង្គម ព្រោះខ្ញុំយល់ពីអារម្មណ៍របស់អ្នករងគ្រោះ ពួកគាត់ត្រូវការជំនួយបំផុតនៅពេលជួបបញ្ហា ខ្ញុំបានធ្វើការស្ម័គ្រចិត្តពីថ្ងៃ ចន្ទ-សុក្រ ។

លោកជំទាវឧកញ៉ាបន្តបន្ថែមថា ដោយសារចំណេះវិជ្ជា និងបទពិសោធន៍ការងារ លោកជំទាវក៏បែកគំនិតរកស៊ីដោយទាក់ទងជាមួយក្រុមហ៊ុនលក់សំបុត្រយន្តហោះ។ បន្ទាប់ពីបានចំណូលពីប្រាក់ខែដែលធ្វើការនៅរោងចក្រ ការងារបកប្រែភាសា និងបានពីការលក់សំបុត្រយន្តហោះ លោកជំទាវឧកញ៉ាក៏បានពង្រីកមុខជំនួញថ្មីបន្ថែមទៀត គឺបើកហាងបាយមួយនៅកូរ៉េ ។

ដោយទទួលបានជោគជ័យ និងភាពរីកចំរើនលើមុខជំនួញ លោកជំទាវឧកញ៉ាក៏សម្រេចចិត្តត្រឡប់មករស់នៅស្រុកកំណើតវិញ ដើម្បីជួយដល់ពលរដ្ឋខ្មែរ ពិសេសស្ត្រី ឱ្យមានការងារធ្វើជៀសផុតពីការធ្វើចំណាកស្រុក បច្ចុប្បន្នលោកជំទាវឧកញ៉ាបានបើកក្រុមហ៊ុន ដេខេប្រធីធីឯ.ក ដែលមានទីតាំងនៅទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ដែលមានបុគ្គលិកបម្រើការងារចំនួន ២០០នាក់ ភាគច្រើនជាស្ត្រី មានទាំងជនជាតិខ្មែរ អ៊ីស្លាម និងកូរ៉េ ។

លោកជំទាវឧកញ៉ាបានបញ្ជាក់ថា ទម្រាំបានមកដល់សព្វថ្ងៃនេះ ***«ជីវិតខ្ញុំស្ថិតក្នុងភាពតស៊ូ និងជួបឧបសគ្គគ្រប់ពេលវេលា»*** អ្វីដែលសំខាន់គឺយើងចេះដាក់គោលដៅខ្លួនឯងឱ្យបានច្បាស់លាស់ ហើយនៅពេលណាមានប្រាក់ត្រូវតែពង្រីកមុខរបរ។

ជាចុងក្រោយ លោកជំទាវបានផ្តាំដល់ស្ត្រីគ្រប់រូបសូមកុំទន់ជ្រាយក្រោកឈរឡើង ចេះដាក់គោលដៅក្នុងជីវិត ហើយមាតាបិតាគ្រប់រូប ដើម្បីឱ្យស្ត្រី ឬកូនស្រីក្លាយជាអ្នកដឹកនាំបាន មានតែទទួលបានការអប់រំ និងចំណេះដឹង ដែលជាគ្រឹះសំខាន់ក្នុងការអភិវឌ្ឍន៍គ្រួសារ និងសង្គមជាតិក្នុងយុគសម័យឌីជីថល៕

# កែច្នៃធុងសំរាមពីសំបកកង់ឡានដែលគេបោះបង់ចោល



អ្នកស្រី **សឿន សុចារី** ជាម្ចាស់សិប្បកម្មធុងបរិស្ថាន ដែលជាសិប្បកម្មមួយកែច្នៃធុងសំរាម ពីសំបកកង់ឡាន ដែលគេបោះចោល ។ អ្នកស្រីគឺជា ស្ត្រីមេម៉ាយម្នាក់ដែលមានកូនពីរនាក់ និងមានបងប្អូនបង្កើតចំនួន៤នាក់ រស់នៅក្នុងគ្រួសារមួយដែលមានជីវភាពមធ្យម ។ ដោយជីវិតជួបនឹងភាពតស៊ូ ភាពលំបាក និងភាពបរាជ័យជាច្រើន ក៏បានប្រែក្លាយជាមេរៀនបទពិសោធន៍ក្នុងជីវិត ជម្រុញឱ្យ អ្នកស្រីគិតឃើញថា ដើម្បីឱ្យខ្លួនមានតម្លៃ និងមានក្តីសុខ គួរតែធ្វើរឿងល្អៗជួយសង្គមតាមរយៈការលះបង់របស់យើង។ អ្នកស្រីបញ្ជាក់បន្ថែមថា៖ «ពេលនោះនាងខ្ញុំគឺជាបុគ្គលិកបម្រើការងារជាមួយក្រុមហ៊ុនឯកជនមួយដោយចិត្តស្រឡាញ់បរិស្ថាន និងការងារសង្គមផង ក្រោយពេលសម្រាកពីការងារនាងខ្ញុំតែងតែចូលរួមរើស និងប្រមូលសំរាមតាមទីសាធារណៈ និងជួយមនុស្សជុំវិញខ្លួនដែលគាត់មានទុក្ខលំបាកជាងយើង ការធ្វើអំពើល្អបានផ្តល់មកខ្ញុំនូវសេចក្តីសុខផ្លូវចិត្តពិតប្រាកដ»។

អ្នកស្រីក៏បានលើកឡើងដែរថា៖ «ខ្ញុំបានសង្កេតឃើញថា បច្ចុប្បន្ននៅលើសកលលោកយើងនេះ មនុស្សបានបង្កើតសំរាមជាច្រើន មិនថារូបខ្ញុំ ឬរូបគេទេ សុទ្ធតែបន្សល់ទុកនូវកាកសំណល់ ដែលធ្វើឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្លាំងបំផុត ព្រោះថាសំបកកង់ឡាន គឺជាវត្ថុដែលមានផលប៉ះពាល់ដល់បរិស្ថានខ្លាំងបំផុត ទោះបីទុកចោលយូររាប់ឆ្នាំមិនងាយរលាយទៅណាដែរ ហើយវាបង្កឱ្យមានការដក់ទឹក បង្កើតឱ្យមានសត្វល្អិត បង្កឱ្យមានជំងឺផ្សេងៗក្នុងសហគមន៍ បើយើងដុតវាចោល ចំហាយផ្សែងវាក៏ធ្វើឱ្យមានផលប៉ះពាល់ដល់សុខភាពយើងផងដែរ»។ ដោយការមើលឃើញបែបនេះ អ្នកស្រីក៏បានប្រឹងប្រែងបង្កើតសិប្បកម្មកែច្នៃសំបកកង់ឡានបរិស្ថានឡើង ។ សិប្បកម្មនេះមានទីតាំងផលិតនៅក្នុងភូមិចំបក់ ឃុំបារាយណ៍ ស្រុកព្រៃឈរ ខេត្តកំពង់ចាម និងឃ្លាំងស្តុកទំនិញនៅទីក្រុងភ្នំពេញ ។

ស្រ្តីវ័យ ៣៣ឆ្នាំ រូបនេះបានបញ្ជាក់ថា មូលហេតុដែលអ្នកស្រីសម្រេចបង្កើតសិប្បកម្មកែច្នៃខុសពីគេនេះ ដោយសារតែកើតចេញពីក្តីស្រឡាញ់ចេញពីបេះដូង «ខ្ញុំជាមនុស្សមានទឹកចិត្តស្រឡាញ់ ការពារបរិស្ថាន និងការងារសង្គម និយាយទៅឱ្យតែការងារទាក់ទងជាមួយបរិស្ថានខ្ញុំចូលចិត្តណាស់» ហើយម្យ៉ាងទៀត អត់សូវឃើញមានអាជីវកម្មណាដែលយកសំបកកង់ឡានដែលលែងប្រើប្រាស់ទៅកែច្នៃឡើងវិញឡើយ និងចង់ចូលរួមថែរក្សាបរិស្ថានផង ណាមួយក៏ចង់បង្កើតឱ្យមានផលិតផល ដែលជាស្នាដៃខ្មែរកាន់តែច្រើននៅលើទីផ្សារផងដែរ ។

អ្នកស្រី **សុចារី** បានបញ្ជាក់ថែមថា «ខ្ញុំបានតស៊ូបង្កើតសិប្បកម្មនេះប្រមាណ១០ឆ្នាំ មកជាមួយនឹងដើមទុនសន្សំមានតែ១៤០ដុល្លារប៉ុណ្ណោះ ។ សិប្បកម្មធុងបរិស្ថានក៏បានបង្កើត ឱកាសការងារ និងប្រាក់ចំណូលដល់ពលរដ្ឋក្នុងស្រុកដែរ ដែលភាគច្រើនជាអ្នកធ្វើស្រែចម្ការ និងកាត់បន្ថយចំណាកស្រុកផងដែរ ។

ធុងសំរាមបរិស្ថានត្រូវបានកែច្នៃជា២ខ្នាតដែលធុងតូចមានតម្លៃ ៣០ដុល្លារ ហើយធុងធំមានតម្លៃ ៤០ដុល្លារ ។ ជាទូទៅក្នុងមួយថ្ងៃអាចលក់បានពី២០ទៅ៣០ធុង ប៉ុន្តែក្នុងវិបត្តិកូវីដ-១៩ បរិមាណលក់បានធ្លាក់មកនៅត្រឹមក្រោម១០ធុង ប៉ុណ្ណោះ ។ ធុងសំរាមនេះមានគុណភាពអាចប្រើប្រាស់បានរយៈ ១០ឆ្នាំ មិនងាយខូច មិនងាយបែក ឬពុកផុយទេ អាចជួយសន្សំថវិកាយើងបានច្រើន។

អ្នកស្រីបន្ថែមទៀតថា៖ ធុងសំរាមបរិស្ថាននេះ គឺជាផលិតផលក្នុងស្រុកមួយ ដែលបង្កើតឡើងដោយស្នាដៃកូនខ្មែរ ប្រសិនបើយើងព្យាយាមលើកស្ទួយ និងជួយផ្សព្វផ្សាយបានទូលំទូលាយ គឺស្មើនឹងយើងបានជួយលើកកម្ពស់ផលិតផលក្នុងស្រុកឱ្យមានតម្លៃលើទីផ្សារ ហើយត្រូវបានគេទទួលស្គាល់ច្រើន ៕



# តារាងស្ថិតសិស្សប្រឡងជាប់សញ្ញាប័ត្រមធ្យម សិក្សាទុតិយភូមិ សម័យប្រឡងឆ្នាំ២០២២

| ល.រ | រាជធានី-ខេត្ត | A | | B | | C | | D | | E | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | ភ្នំពេញ | 268 | 137 | 1335 | 778 | 2870 | 1699 | 4666 | 2497 | 5475 | 2726 |
| 2 | កំពង់ស្ពឺ | 22 | 16 | 217 | 138 | 782 | 502 | 1244 | 754 | 1226 | 627 |
| 3 | ព្រះសីហនុ | 21 | 13 | 116 | 77 | 325 | 184 | 496 | 275 | 406 | 210 |
| 4 | កណ្ដាល | 104 | 46 | 691 | 451 | 1767 | 1094 | 2505 | 1494 | 2482 | 1369 |
| 5 | តាកែវ | 69 | 33 | 542 | 342 | 1424 | 875 | 2228 | 1302 | 2467 | 1298 |
| 6 | កំពត | 36 | 18 | 382 | 241 | 960 | 591 | 1555 | 866 | 1380 | 677 |
| 7 | កែប | 1 | 0 | 22 | 12 | 66 | 33 | 105 | 50 | 89 | 42 |
| 8 | កោះកុង | 5 | 1 | 30 | 15 | 87 | 53 | 187 | 111 | 263 | 156 |
| 9 | កំពង់ចាម | 73 | 44 | 413 | 244 | 1093 | 680 | 1984 | 1199 | 2236 | 1269 |
| 10 | ត្បូងឃ្មុំ | 29 | 21 | 268 | 169 | 781 | 489 | 1297 | 794 | 1249 | 687 |
| 11 | កំពង់ធំ | 26 | 16 | 274 | 162 | 803 | 493 | 1494 | 901 | 1593 | 847 |
| 12 | សៀមរាប | 111 | 61 | 654 | 436 | 1776 | 1123 | 2881 | 1773 | 2689 | 1439 |
| 13 | ព្រះវិហារ | 4 | 3 | 58 | 45 | 257 | 150 | 524 | 319 | 457 | 247 |
| 14 | ក្រចេះ | 29 | 20 | 149 | 88 | 305 | 181 | 544 | 319 | 608 | 312 |
| 15 | ស្ទឹងត្រែង | 3 | 2 | 43 | 26 | 132 | 74 | 288 | 165 | 251 | 119 |
| 16 | ព្រៃវែង | 61 | 37 | 577 | 371 | 1411 | 931 | 1920 | 1142 | 1830 | 1003 |
| 17 | ស្វាយរៀង | 17 | 6 | 206 | 133 | 627 | 379 | 1024 | 595 | 1006 | 521 |
| 18 | កំពង់ឆ្នាំង | 27 | 13 | 218 | 141 | 543 | 345 | 966 | 611 | 1074 | 598 |
| 19 | ប៉ៃលិន | 2 | 2 | 29 | 25 | 66 | 43 | 136 | 87 | 168 | 94 |
| 20 | ពោធិ៍សាត់ | 25 | 13 | 141 | 79 | 419 | 283 | 702 | 426 | 812 | 451 |
| 21 | បាត់ដំបង | 54 | 18 | 433 | 268 | 1192 | 753 | 1978 | 1222 | 2288 | 1278 |
| 22 | ឧត្ដរមានជ័យ | 6 | 5 | 49 | 29 | 215 | 103 | 463 | 260 | 488 | 286 |
| 23 | បន្ទាយមានជ័យ | 49 | 25 | 316 | 189 | 841 | 541 | 1340 | 847 | 1355 | 754 |
| 24 | រតនគិរី | 4 | 2 | 41 | 24 | 192 | 110 | 448 | 265 | 469 | 226 |
| 25 | មណ្ឌលគិរី | 3 | 0 | 28 | 15 | 119 | 68 | 190 | 107 | 143 | 68 |
| | **សរុប** | 1049 | 552 | 7232 | 4498 | 19053 | 11777 | 31165 | 18381 | 32504 | 17304 |

*( ប្រភព៖ មន្ទីរកិច្ចការនារី រាជធានី/ខេត្ត)*

# ស្ថិតស្ត្រីក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៥ (២០២២)

| ល.រ | ឈ្មោះរាជធានី-ខេត្ត | ចំនួនស្រុក/ក្រុង | ចំនួនឃុំ-សង្កាត់ | ស្ត្រីជាមេឃុំ/ចៅសង្កាត់ | ស្ត្រីជាជំទប់ទី ១ | ស្ត្រីជាជំទប់ទី ២ | ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ | ឃុំដែលគ្មានស្ត្រីក្នុងក្រុមប្រឹក្សា |
|---|---|---|---|---|---|---|---|---|
| 1 | ភ្នំពេញ | 14 | 105 | 16 | 22 | 11 | 195 | 2 |
| 2 | កណ្តាល | 11 | 127 | 19 | 21 | 9 | 144 | 0 |
| 3 | កែប | 2 | 5 | 0 | 1 | 1 | 4 | 0 |
| 4 | កំពង់ចាម | 10 | 109 | 6 | 10 | 12 | 106 | 19 |
| 5 | កំពង់ឆ្នាំង | 8 | 71 | 15 | 13 | 9 | 68 | 7 |
| 6 | កំពង់ស្ពឺ | 8 | 88 | 6 | 11 | 9 | 91 | 5 |
| 7 | កំពង់ធំ | 9 | 81 | 4 | 16 | 12 | 85 | 7 |
| 8 | កំពត | 9 | 93 | 6 | 22 | 2 | 82 | 11 |
| 9 | កោះកុង | 7 | 29 | 2 | 5 | 5 | 35 | 0 |
| 10 | ក្រចេះ | 6 | 48 | 5 | 11 | 6 | 51 | 3 |
| 11 | តាកែវ | 10 | 100 | 5 | 19 | 4 | 115 | 15 |
| 12 | ត្បូងឃ្មុំ | 7 | 64 | 2 | 5 | 4 | 98 | 3 |
| 13 | មណ្ឌលគិរី | 5 | 21 | 4 | 7 | 2 | 14 | 0 |
| 14 | បន្ទាយមានជ័យ | 9 | 67 | 5 | 13 | 8 | 71 | 8 |
| 15 | បាត់ដំបង | 14 | 103 | 12 | 27 | 14 | 160 | 3 |
| 16 | ប៉ៃលិន | 2 | 8 | 3 | 3 | 2 | 9 | 0 |
| 17 | ព្រះវិហារ | 8 | 51 | 7 | 7 | 8 | 6 | 2 |
| 18 | ព្រៃវែង | 13 | 116 | 9 | 18 | 6 | 126 | 19 |
| 19 | ពោធិ៍សាត់ | 7 | 49 | 6 | 13 | 10 | 57 | 2 |
| 20 | ព្រះសីហនុ | 4 | 29 | 2 | 5 | 4 | 23 | 8 |
| 21 | រតនគិរី | 9 | 50 | 4 | 7 | 12 | 34 | 3 |
| 22 | សៀមរាប | 12 | 100 | 18 | 32 | 12 | 112 | 5 |
| 23 | ស្ទឹងត្រែង | 6 | 34 | 3 | 12 | 5 | 22 | 1 |
| 24 | ស្វាយរៀង | 8 | 80 | 16 | 20 | 12 | 86 | 3 |
| 25 | ឧត្តរមានជ័យ | 5 | 24 | 1 | 5 | 7 | 31 | 0 |
| **សរុប** | | 203 | 1,652 | 176 | 325 | 186 | 1,825 | 126 |

*( ប្រភព៖ មន្ទីរកិច្ចការនារី រាជធានី/ខេត្ត )*

# ស្ត្រី និងភាពជាអ្នកដឹកនាំថ្នាក់ រាជធានី-ខេត្ត

| ល.រ | រាជធានី-ខេត្ត | ស្ត្រីជាអភិបាល រាជធានី-ខេត្ត | ស្ត្រីជាអភិបាលរង រាជធានី-ខេត្ត | ស្ត្រីជាសមាជិកក្រុមប្រឹក្សា រាជធានី-ខេត្ត | ស្ត្រីជាប្រធានមន្ទីរ រាជធានី-ខេត្ត | ស្ត្រីជាអនុប្រធានមន្ទីរ រាជធានី-ខេត្ត |
|---|---|---|---|---|---|---|
| 1 | ភ្នំពេញ | 0 | 1 | 5 | 3 | 12 |
| 2 | កំពង់ស្ពឺ | 0 | 1 | 3 | 4 | 16 |
| 3 | ព្រះសីហនុ | 0 | 1 | 4 | 3 | 11 |
| 4 | កណ្ដាល | 0 | 1 | 6 | 5 | 20 |
| 5 | តាកែវ | 0 | 1 | 6 | 1 | 16 |
| 6 | កំពត | 0 | 1 | 4 | 2 | 22 |
| 7 | កែប | 0 | 3 | 1 | 2 | 7 |
| 8 | កោះកុង | 1 | 2 | 2 | 2 | 19 |
| 9 | កំពង់ចាម | 0 | 1 | 4 | 4 | 17 |
| 10 | ត្បូងឃ្មុំ | 0 | 1 | 5 | 1 | 7 |
| 11 | កំពង់ធំ | 0 | 1 | 3 | 2 | 9 |
| 12 | សៀមរាប | 0 | 2 | 3 | 1 | 13 |
| 13 | ព្រះវិហារ | 0 | 1 | 2 | 2 | 13 |
| 14 | ក្រចេះ | 0 | 1 | 3 | 2 | 17 |
| 15 | ស្ទឹងត្រែង | 0 | 1 | 3 | 4 | 17 |
| 16 | ព្រៃវែង | 0 | 2 | 4 | 1 | 14 |
| 17 | ស្វាយរៀង | 0 | 2 | 7 | 2 | 17 |
| 18 | កំពង់ឆ្នាំង | 0 | 1 | 3 | 2 | 18 |
| 19 | ប៉ៃលិន | 1 | 1 | 3 | 2 | 15 |
| 20 | ពោធិ៍សាត់ | 0 | 1 | 2 | 2 | 10 |
| 21 | បាត់ដំបង | 0 | 1 | 5 | 1 | 26 |
| 22 | ឧត្តរមានជ័យ | 0 | 2 | 6 | 4 | 6 |
| 23 | បន្ទាយមានជ័យ | 0 | 1 | 6 | 3 | 18 |
| 24 | រតនគីរី | 0 | 1 | 2 | 2 | 16 |
| 25 | មណ្ឌលគីរី | 0 | 1 | 3 | 3 | 23 |
| | **សរុប** | 02 | 32 | 95 | 60 | 379 |

*( ប្រភព៖ មន្ទីរកិច្ចការនារី រាជធានី/ខេត្ត )*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
ក្រុមការងារយេនឌ័រ

# តារាងស្ថិតិមន្ត្រីរាជការស៊ីវិលសរុប នៅតាមក្រសួង-ស្ថាប័ននានា ឆ្នាំ២០២១

| ល.រ | ក្រសួង-ស្ថាប័ន | ចំនួនមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ | | | ចំនួនមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិ | | | ចំនួនមន្ត្រីរាជការស៊ីវិលសរុប | | ភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | សរុបរួម | ស្រី | ស្រី | |
| ១ | ទីស្តីការគណៈរដ្ឋមន្ត្រី | 1,092 | 337 | 1,429 | 0 | 0 | 0 | 1,429 | 337 | 24% | |
| ២ | ព្រះបរមរាជវាំង | 318 | 70 | 388 | 0 | 0 | 0 | 388 | 70 | 18% | |
| ៣ | មហាផ្ទៃ | 1,712 | 449 | 2,161 | 26,269 | 20,649 | 46,918 | 49,079 | 21,098 | 43% | |
| ៤ | ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 511 | 228 | 739 | 0 | 0 | 0 | 739 | 228 | 31% | |
| ៥ | អភិវឌ្ឍន៍ជនបទ | 430 | 190 | 620 | 655 | 214 | 869 | 1,489 | 404 | 27% | |
| ៦ | ពាណិជ្ជកម្ម | 997 | 371 | 1,368 | 268 | 166 | 434 | 1,802 | 537 | 30% | |
| ៧ | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 4,279 | 1,708 | 5,987 | 353 | 241 | 594 | 6,581 | 1,949 | 30% | |
| ៨ | អប់រំ យុវជន និងកីឡា | 3,304 | 1,731 | 5,035 | 62,737 | 56,258 | 118,995 | 124,030 | 57,989 | 47% | |
| ៩ | ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 595 | 149 | 744 | 249 | 124 | 373 | 1,117 | 273 | 24% | |
| ១០ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 591 | 168 | 759 | 1,015 | 248 | 1,263 | 2,022 | 416 | 21% | |
| ១១ | ផែនការ | 642 | 334 | 976 | 792 | 615 | 1,407 | 2,383 | 949 | 40% | |
| ១២ | ធម្មការ និងសាសនា | 406 | 112 | 518 | 663 | 159 | 822 | 1,340 | 271 | 20% | |
| ១៣ | បរិស្ថាន | 727 | 255 | 982 | 1,572 | 139 | 1,711 | 2,693 | 394 | 15% | |
| ១៤ | យុត្តិធម៌ | 311 | 166 | 477 | 1,643 | 634 | 2,277 | 2,754 | 800 | 29% | |
| ១៥ | ប្រៃសណីយ៍ និងទូរគមនាគមន៍ | 645 | 263 | 908 | 229 | 123 | 352 | 1,260 | 386 | 31% | |
| ១៦ | ព័ត៌មាន | 700 | 382 | 1,082 | 312 | 219 | 531 | 1,613 | 601 | 37% | |
| ១៧ | វប្បធម៌ និងវិចិត្រសិល្បៈ | 1,143 | 612 | 1,755 | 414 | 294 | 708 | 2,463 | 906 | 37% | |
| ១៨ | ទេសចរណ៍ | 451 | 224 | 675 | 322 | 192 | 514 | 1,189 | 416 | 35% | |
| ១៩ | សុខាភិបាល | 3,043 | 3,085 | 6,128 | 0 | 0 | 0 | 6,128 | 3,085 | 50% | |
| ២០ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 2,499 | 898 | 3,397 | 825 | 309 | 1,134 | 4,531 | 1,207 | 27% | |
| ២១ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 491 | 378 | 869 | 483 | 361 | 844 | 1,713 | 739 | 43% | |
| ២២ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 2,157 | 856 | 3,013 | 2,326 | 615 | 2,941 | 5,954 | 1,471 | 25% | |
| ២៣ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 493 | 186 | 679 | 350 | 130 | 480 | 1,159 | 316 | 27% | |
| ២៤ | រ៉ែ និងថាមពល | 394 | 116 | 510 | 282 | 67 | 349 | 859 | 183 | 21% | |
| ២៥ | សាធារណការ និងដឹកជញ្ជូន | 1,269 | 287 | 1,556 | 1,139 | 346 | 1,485 | 3,041 | 633 | 21% | |
| ២៦ | កិច្ចការនារី | 62 | 174 | 236 | 79 | 370 | 449 | 685 | 544 | 79% | |
| ២៧ | ធនធានទឹក និងឧតុនិយម | 648 | 197 | 845 | 427 | 101 | 528 | 1,373 | 298 | 22% | |
| ២៨ | មុខងារសាធារណៈ | 474 | 215 | 689 | 284 | 176 | 460 | 1,149 | 391 | 34% | |
| ២៩ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 554 | 201 | 755 | 0 | 0 | 0 | 755 | 201 | 27% | |
| ៣០ | អង្គភាពប្រឆាំងអំពើពុករលួយ | 330 | 169 | 499 | 0 | 0 | 0 | 499 | 169 | 34% | |
| | សរុប គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | 31,268 | 14,511 | 45,779 | 103,688 | 82,750 | 186,438 | 232,217 | 97,261 | | |
| | អត្រាភាគរយ (%) | 68% | 32% | 100% | 56% | 44% | 100% | 100% | 42% | | |

បានឃើញ និងឯកភាព
ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ២០២២
រដ្ឋមន្ត្រី
ព្រំ-សុខា

ថ្ងៃពុធ ៤រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២
ប្រធានក្រុមការងារយេនឌ័រ
ឈី ឌិដ្ឋា

# ស្ត្រីរួមគ្នា រក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍ ក្នុងយុគសម័យឌីជីថល



## Women: Together for Peace and Development in Digital Age

ក្រសួងកិច្ចការនារី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងសប្បុរសជនទាំងអស់ ដែលបានជួយឧបត្ថម្ភគាំទ្រ ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ ខួបលើកទី១១២

*The Ministry of Women's Affairs would like to express its profound thanks to the Royal Government of Cambodia and the following donors who have sponsored the program to mark the 112th International Women's Day, 8th March 2023.*

**នាយកដ្ឋានព័ត៌មាន ក្រសួងកិច្ចការនារី**

ផ្លូវត្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

Department of Information, Ministry of Women's Affairs
Street Trung Morn, Domnak Thom III, Stoeung Meanchey, Khan Meanchey, Phnom Penh